# សុមេធបណ្ឌិត



រៀបរៀងដោយ

ភិក្ខុសុវណ្ណត្ថេរោ **ខង់ ឆំពីរ**

ពុទ្ធសករាជ ២៥៥២

# សុមេធបណ្ឌិត




រៀបរៀងដោយ

ភិក្ខុសុវណ្ណត្ថេរោ ទប់ ឈិព័រ

សម្រាប់ជាធម្មទាន

# អារម្ភកថា

ជីវិតគឺជាប្រភពនៃបញ្ហា ដ៏សែនស្មុគស្មាញ មិនអាចគណនាបាន ។ តើបញ្ហាទាំងនោះដូចម្តេចខ្លះ ? បញ្ហាទាំងនោះគឺ លំបាកក្នុងការស្វែងរកអាហារ សម្រាប់ចិញ្ចឹមជីវិត, ការទាស់ទែងក្នុងក្រុមគ្រួសារ, តែងទទួលនូវការគាបសង្កត់ពីអ្នកដទៃ, មិនមានភាពស្មោះត្រង់ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត, ការព្រាត់ប្រាសបុគ្គលជាទីស្រឡាញ់, ការជួបនូវបុគ្គលដែលខ្លួនមិនពេញចិត្ត, និងការកើត ចាស់ ឈឺ ស្លាប់ជាដើម ។ ទន្ទឹមគ្នានឹងបញ្ហា ដែលមានប្រាកដ ចំពោះមុខយ៉ាងនេះ សត្វលោកម្នាក់ ៗ ក៏ស្វែងរកឧបាយ ដើម្បីដោះស្រាយនូវរាល់បញ្ហាទាំងនោះ តាមជំនឿ និងការយល់ដឹងរបស់ខ្លួន ។ ទោះបីជាសត្វលោក ខំឃ្នាតខ្នីព្យាយាម ស្វែងរកវិធីសាស្ត្រយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចបញ្ចប់នូវបញ្ហាទាំងនោះឲ្យអស់សព្វគ្រប់បាន រឿងមួយស្ងប់បាត់ទៅ រឿងមួយទៀតកើតឡើងជាបន្ត ជាពិសេសការកើត ចាស់ ឈឺ ស្លាប់

ដែលសត្វលោកគ្រប់គ្នា មិនអាចប្រឈមមុខដោះស្រាយបាន មានឧបមាដូចសត្វស្វាប ដែលជាប់សំណាញ់ របស់ព្រាន ហើយ មានចំនួនតិចណាស់ ដែលរួចចេញវិញបាន ដូច្នោះ ។ ព្រោះហេតុតែ ជីវិតសម្បូណ៌ដោយសេចក្តីទុក្ខ និងបញ្ហាស្មុគស្មាញយ៉ាងនេះ ទើបមានបុគ្គលអច្ឆរិយៈ ១ រូប ព្យាយាម បំពេញនូវបារមីទាំងឡាយ យ៉ាងមោះមុត អស់កាលដ៏យូរ រហូតត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដើម្បីជួយដោះស្រាយ នូវវិបត្តិទាំងឡាយ របស់ពពួកសត្វ ។

ដើម្បីបង្ហាញពីវីរភាព និងសេចក្តីអំណត់របស់ព្រះអង្គ ក្នុងការស្វែងរក នូវពោធិញ្ញាណ សម្រាប់ជួយស្រោចស្រង់ សត្វលោក ចេញចាកពីសង្សារវដ្ត ខ្ញុំបានសរសេរសៀវភៅ មួយ ដែលមានឈ្មោះថា **សុមេធបណ្ឌិត** ។

សៀវភៅ **សុមេធបណ្ឌិត** នេះ គឺរៀបរាប់ប្រវត្តិ របស់ព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់នៃយើង ក្នុងកំណើតជា **សុមេធ** នាសម័យកាលនៃព្រះទសពល ព្រះនាមទីបង្ករ ។

ក្នុងការរៀបរៀងនេះ ខ្ញុំបានស្រង់ចាកពីគម្ពីរមួយចំនួន ដែលទាក់ទងនឹងប្រវត្តិរបស់ព្រះអង្គ កាលនៅជា **សុមេធ** ម្យ៉ាងទៀតខ្ញុំបានសរសេរមាតិកាធម៌ផ្សេងៗ ទុក នៅខាងចុងសៀវភៅ ដើម្បីកុំឲ្យស្មុំញាំច្រើន និងងាយស្រួលដល់ការយល់តាមខ្សែរឿងផង ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ដល់ពុទ្ធបរិស័ទអ្នកអាន បើមិនបានច្រើន ក៏គង់តិចតួចដែរ ។ សៀវភៅនេះខ្ញុំខិតខំប្រឹងប្រែងសរសេរ និងឲ្យកិក្ខុសាមណេរអ្នកឈ្លាសមួយចំនួន ជួយពិនិត្យផ្ទៀងផ្ទាត់ យ៉ាងហ្មត់ចត់ ប៉ុន្តែទោះជាយ៉ាងនោះក្តី ក៏គង់មានខុសឆ្គង លើសលោះខ្វះខាតពុំខាន ម្យ៉ាងទៀត នេះគឺជាការរៀបរៀងលើកដំបូងរបស់ខ្ញុំ ព្រោះហេតុនោះ ខ្ញុំសូមទទួលនូវការរិះគន់កែលម្អរបស់ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន ។

សូមលើកនូវកុសលនៃធម្មទាននេះ ប្រគេន និងជូនចំពោះ :

- លោកម្ចាស់គ្រូ វជិរប្បញ្ញោ សាន សុជា ជាអាចារ្យរបស់ខ្ញុំ ។

- ឧបាសិកា សួត្រ សន ញោមស្រីរបស់ខ្ញុំ

- ពុទ្ធបរិស័ទទាំងអស់ អ្នកមានឧបការៈមកលើរូបខ្ញុំ ។

សូមឧទ្ទិសកុសលនេះ ចំពោះ :

- បុរាណបណ្ឌិតខ្មែរគ្រប់ជំនាន់

- ឧបាសក កែវ វ៉ង់ ឧបាសិកា យស ង៉ែត ជីតា និងជីដូន របស់ខ្ញុំ

- ឧបាសក អ៊ុម សូត្រ ឧបាសិកា អ៊ួច ចិន ជីតា និងជីដូនរបស់ខ្ញុំ

- ឧបាសក កែវ សៀន ញោមប្រុសរបស់ខ្ញុំ និងពពួកញាតិ ក្នុងសង្សារវដ្តទាំងអស់ ។

មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន

ថ្ងៃ ១ កើត ខែ ចេត្រ ឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៥៥២

ភិក្ខុសុវណ្ណត្ថេរោ ខង់ ធំព័រ

# មាតិកាធម៌


| ឈ្មោះអត្ថបទ | ទំព័រ |
| --- | --- |
| ប្រវត្តិសុមេធបណ្ឌិត........................................ | ១ |
| ការកសាងផ្នួស និងទទួលពាក្យព្យាករណ៍...... | ២៩ |
| សុមេធបណ្ឌិតពិចារណារកពុទ្ធការកធម៌....... | ៨៤ |
| ទានបារមីទី ១............................................ | ៨៤ |
| សីលបារមីទី ២............................................ | ៨៨ |
| នេក្ខម្មបារមីទី ៣........................................ | ៩១ |
| បញ្ញាបារមីទី ៤........................................... | ៩៥ |
| វីរិយបារមីទី ៥........................................... | ៩៩ |
| ខន្តិបារមីទី ៦............................................. | ១០២ |
| សច្ចបារមីទី ៧............................................. | ១០៦ |
| អធិដ្ឋានបារមីទី ៨....................................... | ១១០ |
| មេត្តាបារមីទី ៩........................................... | ១១៤ |
| ឧបេក្ខាបារមីទី ១០....................................... | ១១៨ |

ពិចារណាបារមីទាំង ១០ ដោយអនុលោមបដិលោម ១២២

មាតិកាធម៌ផ្សេង ៗ ........................................ ១៤០

លក្ខណាទិចតុក្កៈរបស់បារមី ........................ ១៤០

១. ទានបារមី ................................................ ១៤០

២. សីលបារមី ................................................ ១៤១

៣. នេក្ខម្មបារមី ............................................ ១៤១

៤. បញ្ញាបារមី ................................................ ១៤២

៥. វីរិយបារមី ................................................ ១៤៣

៦. ខន្តិបារមី ................................................ ១៤៤

៧. សច្ចបារមី ................................................ ១៤៥

៨. អធិដ្ឋានបារមី ............................................ ១៤៦

៩. មេត្តាបារមី ................................................ ១៤៦

១០. ឧបេក្ខាបារមី ............................................ ១៤៧

**ទីបង្គ្រឹមប្រកបដោយទោស ៥ ប្រការ** .............. ១៤៩

អភិញ្ញាពលៈប្រកបដោយគុណ ៨ ប្រការ...... ១៥០

សំពត់សាដកប្រកបដោយទោស ៩ ប្រការ.... ១៥១

សំពត់សម្បកឈើប្រកបដោយគុណ ១២ ប្រការ. ១៥៣

បណ្ណសាលាប្រកបដោយទោស ៨ ប្រការ...... ១៥៥

គល់ឈើប្រកបដោយគុណ ១០ ប្រការ......... ១៥៧

ធម្មសមោធាន ៨ យ៉ាង................................ ១៥៩

អ្នកជួយពិនិត្យខ្លឹមសារ និងអក្ខរាវិរុទ្ធ............. ១៦១

ឯកសារពិគ្រោះ........................................... ១៦២

នាមពុទ្ធបរិស័ទបរិច្ចាគប្រាក់បោះពុម្ព.............. ១៦៣

# ប្រវត្តិសុមេធបណ្ឌិត

បានឮថា ក្នុងទីបំផុតនៃបួនអសង្ខេយ្យនិងមួយសែនកប្ប រាប់ថយក្រោយអំពីកប្បនេះទៅ មានព្រះនគរមួយឈ្មោះថា អមរវតី ។ ក្នុងសម័យនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ សុមេធ ជាអ្នកមានកំណើតល្អទាំងពីរចំណែក គឺជាអ្នកកាន់យកកំណើតល្អហើយ ទាំងខាងមាតា ទាំងខាងបិតា រហូត ៧ ជួរនៃត្រកូល ដែលបុគ្គលណាមួយមិនអាចមើលងាយ មានសេចក្តីរង្កៀស ដោយជាតិ ត្រកូលជាដើម, ជាអ្នកមានរូបស្អាត គួរជាទីពិតពិលរមិលមើល នាំមកនូវសេចក្តីជ្រះថ្លា ប្រកបដោយសម្បុរ និងទ្រង់ទ្រាយល្អ អាស្រ័យនៅក្នុងនគរអមរវតីនោះ ។ សុមេធព្រាហ្មណ៍នោះ មិនបានធ្វើការងារដទៃណាទីមួយឡើយ គឺគ្រាន់តែសិក្សានូវសិល្ប៍-សាស្ត្ររបស់ព្រាហ្មណ៍ប៉ុណ្ណោះ ។ មាតានិងបិតាបានធ្វើ

មរណកាល តាំងពីសុមេធព្រាហ្មណ៍នៅវ័យក្មេងនៅឡើយ ។ សម័យនោះ មានអាមាត្រម្នាក់ឈ្មោះរាសិវឌ្ឍកៈ ជានាយឃ្លាំងចាត់ចែងនូវកេរ្តិ៍មរតក បាននាំយកនូវអាយបោត្ថកៈ ( បញ្ជីកត់ត្រាចំនួនទ្រព្យសម្បត្តិ ) មកបើកត្រង់ឃ្លាំងដែលពេញដោយមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម ហើយប្រាប់នូវទ្រព្យសម្បត្តិទាំង ៧ ជួរ នៃត្រកូលឲ្យសុមេធព្រាហ្មណ៍បានជ្រាបថា ម្នាលកុមារ ទ្រព្យមានចំនួនប៉ុណ្ណេះ ជាចំណែកខាងមាតា ទ្រព្យមានចំនួនប៉ុណ្ណេះ ជាចំណែកខាងបិតា និងទ្រព្យមានចំនួនប៉ុណ្ណេះ ជាចំណែកខាងជីដូនជីតានៃអ្នក ចូរអ្នកថែរក្សាប្រើប្រាស់ នូវទ្រព្យទាំងនេះចុះ ។

សុមេធបណ្ឌិត កាលបើបានស្តាប់ពាក្យទាំងអស់នេះហើយ ក៏មានសេចក្តីសង្វេគគិតថា ញាតិជាទីស្រឡាញ់ទាំងឡាយ មានបិតានិងជីតាជាដើម របស់អាត្មាអញ

តែងសន្សំទុកដាក់ នូវទ្រព្យសម្បត្តិទាំងនេះ លុះទៅកាន់បរលោក មិនបានកាន់យកទ្រព្យសូម្បីមួយកហាបណៈសោះ ចំណែកអាត្មាអញគួរធ្វើនូវឧបាយណាមួយដែលគប្បីកាន់យកទៅបានទើបសមគួរ ។ ព្រោះហេតុតែការយល់ឃើញយ៉ាងនេះហើយ ក៏ក្រាបទូលដល់ព្រះរាជាឲ្យទូងស្គរប្រកាសក្នុងព្រះនគរ បរិច្ចាគទានដល់មហាជន រួចចេញបួសជាតាបស ។

ពិតមែន រឿងសុមេធតាបសនេះ លោកពោលទុកក្នុងពុទ្ធវង្ស[១] ទីបង្ករទី ១ ថា :

កប្បេ ច សតសហស្សេ ចតុរោ ច អសង្ខិយេ
អមរំ នាម នគរំ ទស្សនេយ្យំ មនោរមំ ។
ទសហិ សទ្ទេហិ អវិវិត្តំ អន្នបានសមាយុតំ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំស: លេខ ៧៧ ។

**ហត្ថិសទ្ទំ អស្សសទ្ទំ ភេរិសទ្ទរថានិ ច ។**

ក្នុង ៤ អសង្ខេយ្យ និងមួយសែនកប្ប
មាននគរឈ្មោះ អមរវតី ជានគរគួរពិតពិល
រមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូណ៌
ដោយបាយនិងទឹក ទាំងមិនស្ងាត់ដោយមាន
សម្លេង ១០ យ៉ាងគឺ[១] សម្លេងដំរី សម្លេងសេះ
សម្លេងស្គរ សម្លេងស័ង្ខ និងសម្លេងរថជាដើម ។

**ខាទថ បិវថ ចេវ អន្នបានេន ឃោសិតំ**

**នគរំ សព្វង្គសម្បន្នំ សព្វកម្មុបាគតំ ។**

ទាំងជានគរ គឹកកងដោយសម្លេង ដែល
ប្រកបដោយបាយ និងទឹកថា ចូរស៊ី ចូរផឹក
ជានគរសម្បូណ៌ដោយសត្វ និងគ្រឿងឧបករណ៍

---

១-សម្លេង ១០ យ៉ាងនោះគឺ សម្លេងដំរី, សម្លេងសេះ, សម្លេងស្គរ, សម្លេងស័ង្ខ, សម្លេងរថ, សម្លេងពិណ, សម្លេងស្គរសម្ភោរ, សម្លេងគាំងវង់ខែល, សម្លេងស្គរតូច និងសម្លេងហៅមកបរិភោគនូវអាហារ ។ អដ្ឋសាលិនី និងជាតកដ្ឋកថា ។

ទាំងពួង បរិបូណ៌ដោយការងារគ្រប់យ៉ាង ។

សត្តរតនសម្បន្នំ នានាជនសមាកុលំ

សមិទ្ធំ ទេវនគរំវ អាវាសំ បុញ្ញកម្មិនំ ។

បរិបូណ៌ដោយកែវ ៧ ប្រការ កុះករដោយ

ជនជាតិផ្សេង ៗ សម្រេច(ដោយគ្រឿងបរិភោគ

និងឧបភោគទាំងពួង) ដូចជានគរនៃទេវតា ជាទី

នៅនៃជនអ្នកមានបុណ្យទាំងឡាយ ។

នគរេ អមរវតិយា សុមេធោ នាម ព្រាហ្មណោ

អនេកកោដិសន្និចយោ បហូតធនធញ្ញវា ។

វេលានោះ មានសុមេធព្រាហ្មណ៍នៅក្នុង

នគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ

មានទ្រព្យ និងស្រូវច្រើន ។

អជ្ឈាយិកោ មន្តធរោ តិណ្ណំ វេទាន បារគូ

លក្ខណេ ឥតិហាសេ ច សធម្មេ បារមឹ គតោ ។

ជាអ្នករៀនមន្ត ចងចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមី ក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ។[១]

ក្រោយមកថ្ងៃមួយ សុមេធបណ្ឌិត បានចូលទៅសម្ងំក្នុងទីស្ងាត់ នាផ្ទៃប្រាសាទជាន់លើ អង្គុយតាំងសមាធិគិតថា នៃ៎បណ្ឌិត ការបដិសន្ធិក្នុងភពថ្មីទៀតជាទុក្ខ ការបែកធ្លាយសរីរៈក៏ជាទុក្ខដូចគ្នា អាត្មាអញមានជាតិ ជរា ព្យាធិ មរណៈជាធម្មតា ប្រសិនបើអាត្មាអញស្ថិតនៅក្នុងសភាពបែបនេះ គួរតែស្វែងរកនូវព្រះនិព្វាន ដែលមិនមានជាតិ ជរា ព្យាធិ មរណៈ មិនមានទុក្ខ មានតែសេចក្តីសុខតែម្យ៉ាង, មគ្គ(ផ្លូវ)ណាមួយដែលរួចចាកភព មានប្រក្រតីនាំទៅកាន់ព្រះនិព្វាន

---

១-វេទទាំង ៣ បានដល់ ឥរុវេទ ១. យជុវេទ ១. សាមវេទ ១. ។ លក្ខណៈ បានដល់ លក្ខណៈសាស្ត្រ មានលក្ខណៈស្ត្រី លក្ខណៈបុរស និងមហាបុរិសលក្ខណៈ ។ គម្ពីរឥតិហាសៈជាគម្ពីរពិសេស ពោលគឺបុរាណគតិ ដែលប្រកបដោយពាក្យយ៉ាងនេះថា និយាយត ៗ គ្នាដូច្នេះ និយាយត ៗ គ្នាដូច្នេះ ។ មធុរត្ថវិលាសិនី ។

នឹងមានពិតប្រាកដ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

រហោគតោ និសីទិត្វា ឯខំ ចិន្តេសិហន្ទនា
ទុក្ខា បុនព្ភវោ នាម សរីរស្ស បភេទនំ ។
សម្មោហំ មរណំ ទុក្ខំ ជរាយ អតិមទ្ទិតំ
ជាតិធម្មោ ជរាធម្មោ ព្យាធិធម្មោ ចហន្ទនា
អជរំ អមរំ ខេមំ បរិយេសិស្សាមិ និព្វុតី ។

កាលនោះ តថាគត នៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្ដីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្ដីទុក្ខដូចគ្នា(សេចក្ដីស្លាប់ប្រកបដោយមោហៈនាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ) អាត្មាអញ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញ នឹងស្វែងរក

ព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទី

ក្សេមក្សាន្ត ។

**យន្នូនិមំ បូតិកាយំ នានាកុណបបូរិតំ**

**ឆឌ្ឌយិត្វាន គច្ឆេយ្យំ អនបេក្ខោ អនត្ថិកោ ។**

បើដូច្នោះ អាត្មាអញ គួរតែលះបង់កាយ

ស្អុយនេះ ដែលពេញដោយសាកសពផ្សេង ៗ

ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ

ហើយនឹងចេញទៅ ។

**អត្ថិ ហេហិតិ សោ មគ្គោ ន សោ សក្កា ន ហេតុយេ**

**បរិយេសិស្សាមិ តំ មគ្គំ ភវតោ បរិមុត្តិយា ។**

ផ្លូវនោះនឹងមានពិត ផ្លូវនោះ មិនមែនជា

មិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញ

នឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។

ក្រោយមកទៀត សុមេធបណ្ឌិត ក៏បានគិតក្រៃលែងជាងមុនទៀតថា ធម្មតាសុខដែលជាបដិបក្ខនឹងទុក្ខមាននៅក្នុងលោក យ៉ាងណា កាលបើភពមាន ធម៌ដែលប្រាសចាកពោលគឺបដិបក្ខនឹងភព ក៏មានយ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ ដែលជាគ្រឿងរម្ងាប់នូវក្តៅនោះក៏មានយ៉ាងណា ព្រះនិព្វានដែលជាធម៌រម្ងាប់នូវភ្លើង មានរាគៈជាដើម ក៏មានយ៉ាងនោះដែរ ។ ធម៌ល្អមិនមានទោសដែលជាបដិបក្ខជាមួយនឹងធម៌បាបលាមកមាន យ៉ាងណា កាលបើជាតិដ៏លាមកមាន ព្រះនិព្វាន ពោលគឺការមិនមានជាតិ ដែលជាគ្រឿងញ៉ាំងការកើតឡើងឲ្យអស់ទៅ ក៏មានយ៉ាងនោះដែរ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

**យថាបិ ទុក្ខេ វិជ្ជន្តេ សុខំ នាមបិ វិជ្ជតិ**

**ឯវំ ភវេ វិជ្ជមានេ វិភវោ ឥច្ឆិតព្វកោ ។**

កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើកពមាន ការប្រាសចាកកព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។

**យថាបិ ឧណ្ហេ វិជ្ជន្តេ អបរំ វិជ្ជតិ សីតលំ**

**ឯវំ តិវិធគ្គិ វិជ្ជន្តេ និព្វានំ ឥច្ឆិតព្វកំ ។**

កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វាន ដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះដែរ ។

**យថាបិ បាបេ វិជ្ជន្តេ កល្យាណមបិ វិជ្ជតិ**

**ឯវមេវ ជាតិ វិជ្ជន្តេ អជាតិ ឥច្ឆិតព្វកំ ។**

កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមាន ព្រះនិព្វាន មិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នា ក៏មានយ៉ាងនោះដែរ ។

កាលបើសុមេធបណ្ឌិត គិតយ៉ាងនេះហើយ ក៏បានគិតដោយប្រការផ្សេងទៀតថា បុរសអ្នកធ្លាក់ទៅក្នុងរណ្តៅលាមក ឃើញស្រះធំ ពេញដោយទឹក ដេរដាសដោយផ្កាឈូកទាំងឡាយ ៥ ពណ៌ អំពីចម្ងាយ គួរស្វែងរកស្រះនោះ ដោយគិតថា អាត្មាអញគប្បីទៅកាន់ស្រះនោះតាមផ្លូវណាហ្ន៎! ការមិនស្វែងរកស្រះនោះ មិនមែនជាទោសនៃស្រះទេ ជាទោសរបស់បុរសនោះប៉ុណ្ណោះ យ៉ាងណាមិញកាលបើស្រះធំ គឺអមតមហានិព្វាន ជាទីលាងជម្រះនូវមន្ទិលគឺកិលេសមានហើយ បុគ្គលមិនស្វែងរកស្រះនោះសម្រាប់លាង ទោសនោះ មិនមែនជាទោសនៃស្រះធំគឺអមតមហានិព្វានទេ គឺជាទោសរបស់បុរសនោះប៉ុណ្ណោះក៏យ៉ាងនោះដែរ ។ ម្យ៉ាងទៀត បុរសដែលត្រូវសត្រូវឡោមព័ទ្ធ កាលបើផ្លូវសម្រាប់រត់គេចទៅមាន តែបុរសនោះមិនរត់ទៅទេ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ គឺជា

ទោសរបស់បុរសនោះប៉ុណ្ណោះ យ៉ាងណា បុគ្គលត្រូវកិលេស រួបរឹតហើយ កាលបើផ្លូវផុតភ័យជាទីទៅកាន់ព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ គឺជាទោសរបស់បុគ្គលនោះប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។ មួយវិញទៀត បុរសដែលត្រូវជម្ងឺបៀតបៀនហើយ កាលបើពេទ្យអ្នកព្យាបាលជម្ងឺមាន មិនស្វែងរកពេទ្យដើម្បីព្យាបាល ទោសនោះ មិនមែនជាទោសនៃពេទ្យទេ គឺជាទោសរបស់បុរសនោះ យ៉ាងណា បុគ្គលត្រូវជម្ងឺគឺកិលេសបៀតបៀនហើយ មិនស្វះស្វែងរកអាចារ្យជាអ្នកឆ្លាតក្នុងការកម្ចាត់បង់នូវកិលេស ទោសនោះ មិនមែនជាទោសនៃអាចារ្យ អ្នកញ៉ាំងនូវកិលេសឲ្យអស់ទៅទេ គឺជាទោសរបស់បុគ្គលនោះឯង ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

**យថា គូថគតោ បុរិសោ គឡាកំ ឧិស្វាន បូរិតំ**
**ន គវេសតិ គឡាកំ ន ទោសោ គឡាកស្ស សោ។**

ឯទំ កិលេសមលចោទនំ ទិដ្ឋវន្តេ អមគន្តុឡេ

ន គវេសតិ តឡាកំ ន ទោសោ អមតន្តុឡេ ។

បុរសដែលប្រឡាក់លាមក ឃើញស្រះ ពេញដោយទឹក ហើយមិនស្វែងរកស្រះ ទោស នោះ មិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើ ស្រះគឺព្រះនិព្វានមានហើយ បុគ្គល មិនស្វែងរកស្រះ សម្រាប់លាង នូវកិលេស ជាមន្ទិលចេញទេ ទោសនោះ មិនមែនជាទោស នៃស្រះគឺនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាង នោះដែរ ។

យថា អរីហិ បរិរុទ្ធោ ទិដ្ឋវន្តេ គមនំបថេ

ន បលាយតិ សោ បុរិសោ ន ទោសោ អញ្ជសស្ស សោ ។

ឯទំ កិលេសបរិរុទ្ធោ ទិដ្ឋមានេ សិវេ បថេ

ន គវេសតិ តំ មគ្គំ ន ទោសោ សិវមញ្ជសេ។

បុរស ដែលត្រូវសត្រូវទាំងឡាយបោមព័ទ្ធ ហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេសរួបរឹត ហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោស របស់បុគ្គលនោះឯង យ៉ាងនោះដែរ ។

យថា ព្យាធិតោ បុរិសោ វិជ្ជមានេ តិកិច្ឆកេ

ន តិកិច្ឆាបេតិ តំ ព្យាធឹ ន សោ ទោសោ តិកិច្ឆកេ។

ឯវំ កិលេសព្យាធីហិ ទុក្ខិតោ បរិបីឡិតោ

ន គវេសតិ អាចរិយំ ន សោ ទោសោ វិនាយកេ។

បុរសដែលមានជម្ងឺ កាលបើពេទ្យមាន តែមិន ឲ្យពេទ្យនោះ ព្យាបាលជម្ងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គល ត្រូវជម្ងឺ គឺកិលេសទាំងឡាយ បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោស នោះ មិនមែនជាទោសនៃអាចារ្យទេ គឺជាទោស របស់បុគ្គលនោះឯង យ៉ាងនោះដែរ ។

លុះគិតដូច្នេះហើយ ទើបសុមេធបណ្ឌិត គិតថែមទៀត ថា បុរសដែលចូលចិត្តស្អិតស្អាងរាងកាយ បានស្រាយ នូវសាកសព ដែលជាប់ព្ធក់ គប្បីជាអ្នកមានសេចក្តីសុខ យ៉ាងណាមិញ អាត្មាអញ គួរលះបង់នូវកាយស្អុយនេះ ដោយមិនមានអាឡោះអាល័យ ចូលទៅកាន់និព្វានទគរ ក៏យ៉ាងនោះឯង ។ ម្យ៉ាងទៀត បុរសស្ត្រីទាំងឡាយ

បន្ទាបង់នូវឧច្ចារៈ បស្សាវៈក្នុងបង្គន់ហើយ រមែងមិនប្រមូលយក ឬវេចខ្ចប់ដោយសំពត់ទៅទេ ដោយពិតនាំគ្នាទៅដោយមិនមានសេចក្តីអាឡោះអាល័យ ឥតមានសេចក្តីត្រូវការយ៉ាងណា អាត្មាអញគួរលះបង់ចោល នូវកាយស្អុយនេះដោយមិនអាឡោះអាល័យ ហើយចូលទៅកាន់និព្វាននគរយ៉ាងនោះដែរ ។ មួយទៀត ម្ចាស់ទូកទាំងឡាយ តែងលះបង់នូវទូកចាស់ ដែលពុកផុយលិចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណា អាត្មាអញនឹងលះបង់កាយស្មោកគ្រោក ដែលមានរន្ធ ៩ ហូរជាប់ជានិច្ចដោយមិនមានសេចក្តីអាឡោះអាល័យ ហើយចូលទៅកាន់និព្វានបុរី ក៏យ៉ាងនោះដែរ ។ មួយវិញទៀត បុរសខ្លះកាន់យករតនៈផ្សេង ៗ ដើរទៅជាមួយនឹងពួកចោរ ឃើញភ័យអំពីការខាតបង់នូវរតនៈដែលខ្លួនកាន់យកទៅ ទើបលះ

បង់ពួកចោរទាំងនោះហើយទៅ យ៉ាងណាមិញ ករជកាយ (កាយដែលកើតពីធូលី) ក៏មានឧបមាដោយមហាចោរ បើអាត្មាអញ បង្កើតនូវតណ្ហាក្នុងកាយនេះ ធម្មតនៈដែលជាកុសល ពោលគឺអរិយមគ្គនឹងសាបសូន្យទៅ បើដូច្នោះគួរតែអាត្មាអញ លះបង់នូវកាយ ដែលមានឧបមាដូចជាមហាចោរនេះចោល រួចចូលទៅកាន់និព្វានទគរ ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

**យន្តនិមំ បូតិកាយំ នានាកុណបបូរិតំ**

**ឆឌ្ឌយិត្វាន គច្ឆេយ្យំ អនបេក្ខោ អនត្ថិកោ ។**

(បើដូច្នោះ) គួរតែអាត្មាអញ លះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេង ៗ ចេញ គប្បីជាអ្នកមិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការរូប ហើយចេញទៅ ។

យថាបិ កុណបំ បុរិសោ  កណ្ឋេ ពន្ធំ ជិគុច្ឆិយំ
មោចយិត្វាន គច្ឆេយ្យ  សុខី សេរី សយំ វសី ។
តថេវិមំ បូតិកាយំ  នានាកុណបសញ្ចយំ
ឆឌ្ឌយិត្វាន គច្ឆេយ្យំ  អនបេក្ខោ អនត្ថិកោ ។

បុរសបានស្រាយសាកសព ដ៏គួរខ្ពើមរអើម ដែលជាប់ពួដ៏ក គប្បីជាអ្នកមានសេចក្តីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេង ៗ ចេញ ហើយគប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការចេញទៅ យ៉ាងនោះដែរ ។

យថា ឧច្ចារដ្ឋានម្ហិ  ករីសំ នរនារិយោ
ឆឌ្ឌយិត្វាន គច្ឆន្តិ  អនបេក្ខា អនត្ថិកា ។

ឯវរមេខាហំ ឥមំ កាយំ នានាកុណបបូរិតំ

ឆឌ្ឌយិត្វាន គច្ឆិស្សំ វច្ចំ កត្វា យថា កុដី ។

បុរសស្ត្រីទាំងឡាយ ទៅបន្ទោបង់នូវករីសៈ ក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញ នឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេង ៗ ចេញទៅ ដូចបុរសស្ត្រីទាំងឡាយ ដែលបន្ទោបង់វច្ចៈក្នុងបង្គន់ដូច្នោះឯង ។

យថាបិ ជជ្ជរំ នាវំ បលុគ្គំ ឧទកគាហិនី

សាមិកា ឆឌ្ឌយិត្វាន អនបេក្ខា អនគ្គិកា ។

ឯវរមេខាហំ ឥមំ កាយំ នវច្ឆិទ្ទំ ធុវស្សវំ

ឆឌ្ឌយិត្វាន គច្ឆិស្សំ ជិណ្ណនាវំវ សាមិកា ។

ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលិចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានវន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកលះបោលទូកចាស់ដូច្នោះឯង ។

យថា បុរិសោ ចោរេហិ គច្ឆន្តោ ភណ្ឌមាទិយ
ភណ្ឌច្ឆេទភយំ ទិស្វា ឆឌ្ឌយិត្វាន គច្ឆតិ ។
ឯវមេវ អយំ កាយោ មហាចោរសមោ វិយ
បហាយិមំ គមិស្សាមិ កុសលច្ឆេទនា ភយា ។

បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យក៏លះបង់ហើយដើរទៅ យ៉ាងណា កាយនេះ

ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញ នឹង
លះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុលសធម៌
យ៉ាងនោះដែរ ។

សុមេធបណ្ឌិត កាលបើបានគិតដល់នេក្ខម្មដោយឧបមាផ្សេង ៗ យ៉ាងនេះហើយ ក្នុងកាលនោះ ក៏បានលះបង់នូវភោគសម្បត្តិរបស់ខ្លួនមិនមានសេសសល់ ដល់មហាជនមានជនកំព្រា និងអ្នកដើរផ្លូវជាដើម ដូចពោលហើយខាងដើម ។ លុះបរិច្ចាគមហាទាន លះនូវវត្ថុកាមនិងកិលេសកាមរួចហើយ ក៏ចេញចាកអមរនគរ[១] ដែលស្មើដោយទេវនគរដ៏ប្រសើរ ទៅតែម្នាក់ឯង អាស្រ័យនៅនឹងធម្មិកបព៌ត នាព្រៃហិមពាន្ត ដែលជាទីសម្បូរដោយបក្សាបក្សីគ្រប់ប្រភេទ, ធ្វើនូវអាស្រម សាងបណ្ណសាលា និងទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ លះបង់សំពត់សាដក

១-ហៅ អមរវតីនគរ ឬអមរនគរ ក៏បាន ។

ដែលប្រកបដោយទោស ៩ ប្រការ ស្លៀកសំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២ ប្រការ ដើម្បីនាំមកនូវអភិញ្ញា ដែលប្រកបដោយគុណ ៨ ប្រការ ហើយបួសជាតាបស ។ កាលសុមេធតាបស បានបួសស្រេចហើយ ក៏បានលះបង់នូវបណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ ចូលទៅអាស្រ័យនៅទីគល់ឈើ ដែលប្រកបដោយគុណ ១០ ប្រការ លះបង់នូវធញ្ញជាតិដែលគេព្រោះគ្រប់ប្រភេទ បរិភោគតែផ្លែឈើដែលជ្រុះឯងតាមប្រក្រតី ប្រារព្ធនូវសេចក្ដីព្យាយាម ដោយការអង្គុយ ឈរ និងចង្ក្រម ក៏លុះសមាបត្តិ ៨ និងអភិញ្ញា ៥ ក្នុងរវាង ៧ ថ្ងៃ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

**ឯវាហំ ចិន្តយិត្វាន　　នេកកោដិសតំ ធនំ**

**នាថានាថានំ ទត្វាន　　ហិមវន្តំ ឧបាគមឹ ។**

លុះតថាគត គិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។

**ហិមវន្តស្សាវិទូរេ ធម្មិកោ នាម បព្វតោ**

**អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា[១] ។**

មានភ្នំមួយ ឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ ។

---

១-បណ្តាគាថាទាំងនោះ ព្រះបាលីថា *អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា* (តថាគតធ្វើអាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ) លោកពោលដល់ បណ្ណសាលា និងទីចង្រ្កមដែលហាក់បីដូចជាសុមេធបណ្ឌិតកសាងដោយដៃខ្លួនឯង ប៉ុន្តែគាថានេះ មានសេចក្តីដូចតទៅនេះ សក្កទេវរាជទ្រង់ជ្រាបថា ព្រះបរមពោធិសត្វ ចូលទៅកាន់ព្រៃហិមពាន្ត ហើយក្នុងថ្ងៃនេះ នឹងចូលទៅដល់ភ្នំធម្មិកៈ ទើបត្រាស់បញ្ជាវិស្សុកម្មទេវបុត្រថា សុមេធបណ្ឌិតចេញមកដោយគិតថា អាត្មាអញនឹងបួស លោកចូរនិមិត្ត នូវទីសម្រាប់អាស្រ័យនៅដល់ព្រះមហាសត្វអង្គនោះចុះ ។ វិស្សុកម្មទេវបុត្រ បានទទួលពាក្យបញ្ជារបស់សក្កទេវរាជហើយ ក៏បាននិមិត្តអាស្រមដែលគួររីករាយ បណ្ណសាលា ដែលសាងយ៉ាងល្អ និងទីចង្រ្កមជាទីពេញចិត្ត ។ ប៉ុន្តែព្រះមានព្រះភាគ ទ្រង់អាស្រ័យនៅក្នុងអាស្រមបទនោះ ជាផលដែលសម្រេចដោយអានុភាព នៃបុណ្យរបស់ព្រះអង្គ ទើបត្រាស់ថា ម្នាលសារីបុត្រ

**ចង្កមំ តត្ថ មាបេសឹ បញ្ចទោសវិវជ្ជិតំ**

**អដ្ឋគុណសមុបេតំ អភិញ្ញាពលមាហរឹ ។**

*តថាគត និមិត្តនូវទីចង្ក្រម ដែលប្រាសចាក ទោស ៥ ប្រការ(*) នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពលៈ ដែលប្រកបដោយគុណ ៨ ប្រការ(*) ។*

**សាដកំ បជហឹ តត្ថ នវទោសមុបាគតំ**

**វាកចីរំ និវាសេសឹ ទ្វាទសគុណមុបាគតំ ។**[១]

---

*ក្នុងម្ទិកៈនោះ តថាគតបានសាងអាស្រមយ៉ាងល្អ និមិត្តបណ្ណសាលាដ៏ប្រណិត ទាំងនិមិត្តទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ នៅជិតអាស្រមបទនោះផង ។ អដ្ឋសាលិនី និងជាតកដ្ឋកថា ។*

** គ្រប់លេខយោងទាំងអស់ ដែលមានសញ្ញាផ្កាយ(*) ប្រសិនបើចង់ជ្រាបច្បាស់ សូមមើលមាតិកាធម៌នីមួយ ៗ នៅខាងចុងសៀវភៅចាប់ពីទំព័រ ១៤០ ដល់ ១៦០ ។*

*១-ក្នុងគាថានេះ បាទគាថាថា* **សាដកំ បជហឹ តត្ថ** *នវទោសមុបាគតំ(លះបង់សំពត់សាដក ដែលប្រកបដោយទោស ៩ ប្រការក្នុងអាស្រមបទនោះ) មានអនុបុព្វីកថាដូចតទៅនេះ :*

*បានឮថា ក្នុងកាលនោះ កាលដែលវិស្សុកម្មទេវបុត្រ និមិត្តវត្ថុទាំងពួង ដែលជាគ្រឿងសម្រាប់ប្រើប្រាស់ របស់ពួកបព្វជិតយ៉ាងនេះគឺ និមិត្តអាស្រម ដែលប្រដាប់ដោយកុដិ*

លះបង់សំពត់សាដក ដែលប្រកបដោយ
ទោស ៩ ប្រការ(*) ក្នុងអាស្រមបទនោះ ស្លៀក
សំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២
ប្រការវិញ(*) ។

---

លេណា(ទីពួនសម្ងំ) និងទីចង្ក្រមជាដើម ដែលដេរដាសដោយដើមឈើ មានផ្កា និងផ្លែ និងស្រះទឹកថ្លាស្អាតគួរជាទីអភិរម្យ ប្រាសចាកពាលម្រឹគ(សត្វសាហាវ) និងសំឡេងនៃសកុណជាតិ(សត្វស្លាប)ដែលគួរខ្លាច សមគួរដល់សេចក្ដីស្ងប់ស្ងាត់ រៀបចំតាក់តែងផែនក្ដាសម្រាប់ផ្អែក ក្នុងទីបំផុតនៃចំណែកទាំងសងខាងរបស់ទីចង្ក្រម និមិត្តផ្ទាំងសិលាមានផ្ទៃរាបស្មើគ្នា មានពណ៌ដូចសណ្ដែកបាយទុកត្រង់កណ្ដាលនៃទីចង្ក្រម ដើម្បីប្រយោជន៍ដល់ការអង្គុយ ។ និមិត្តនូវបរិក្ខារតាបស មាន**ជដាមណ្ឌល** (រមួរសក់កណ្ដាញ់), **វាកចីរ**(សំពត់សម្បកឈើ), **តិទណ្ឌ**(ឈើមានជើង៣), **កុណ្ឌី** (កាជនៈសម្រាប់ដាក់ទឹក) ជាដើម ទុកក្នុងបណ្ណសាលា ។ និមិត្តក្អមទឹកសម្រាប់ឆាន់ ស័ង្ខដងទឹកឆាន់ និងផ្ដិលទឹកឆាន់ទុកក្នុងមណ្ឌប(រោងបាំ) ។ និមិត្តអំបែងរងើកភ្លើង និងអុសជាដើម ទុកក្នុងរោងភ្លើង ហើយចារឹកអក្សរនៅនឹងជញ្ជាំងបណ្ណសាលាថា ប្រសិនបើ បុគ្គលណា ប្រាថ្នានឹងបួស ចូរកាន់យកនូវបរិក្ខារទាំងនេះហើយបួសចុះ ។ វិស្សុកម្មទេវបុត្រ លុះបាននិមិត្តយ៉ាងនេះរួចស្រេចហើយ ក៏ត្រឡប់ទៅកាន់ទេវលោកវិញ ។ សុមេធបណ្ឌិត កាលជ្រើសរើសរកទីកន្លែងដែលសមរម្យគួររីករាយ អាចជាទីអាស្រ័យនៅរបស់ខ្លួន ក៏ចូលទៅតាមច្រកជាចន្លោះនៃភ្នំហិមពាន្ត ហើយក៏បានឃើញអាស្រមបទ ដែលសក្កទេវរាជបញ្ជាឲ្យវិស្សុកម្មទេវបុត្រនិមិត្តថ្វាយ ដែលជាទីគួររីករាយនៅជិតស្ទឹង ទើបចូលទៅកាន់ទីបំផុតនៃទីចង្ក្រម ។ លុះចូលទៅដល់ហើយ ក៏គិតថា បព្វជិតអ្នកនៅជាប្រចាំ ទៅភិក្ខាចារក្នុងស្រុកជិត ៗ នឹងជាអ្នកមានរាងកាយលំបាកនឿយហត់ ត្រឡប់មកវិញ ចូលទៅកាន់បណ្ណសាលាហើយអង្គុយចុះ ដូច្នេះរង់ចាំបន្តិចសិន រួចគិតទៀតថា បព្វជិតនេះទៅយូរណាស់

## អដ្ឋទោសសមាកិណ្ណំ          បជហី បណ្ណសាលកំ

## ឧបាគមឹ រុក្ខមូលំ          គុណេហិ ទសហុបាគតំ ។[១]

*លះបង់បណ្ណសាលា ដែលប្រកបដោយទោស*

*៨ ប្រការ(*) ចូលទៅកាន់គល់ឈើ ដែលប្រកប*

*ដោយគុណ ១០ យ៉ាង(*) ។*

---

អាត្មាអញនឹងដឹងបានដោយលំបាក ហើយទើបចូលទៅបើកទ្វារបណ្ណសាលា ពិនិត្យមើលខាងនេះ ខាងនោះ ក៏អានទូវអក្សរដែលនៅលើជញ្ជាំងជំ ក៏សម្គាល់ថា កប្បិយបរិក្ខារទាំងនេះ ជារបស់អាត្មាអញ អាត្មាអញនឹងកាន់យកបរិក្ខាទាំងនេះដើម្បីបួស ទើបលះបង់សំពត់សាដកទាំងគូដែលខ្វនស្មៀក និងដណ្តប់ចេញ ។ ដោយហេតុនោះ ទើបត្រាស់ថា តថាគតលះបង់សំពត់សាដកចោលក្នុងបណ្ណសាលានោះ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលសារីបុត្រ តថាគតចូលទៅដោយអាការៈយ៉ាងនេះ ហើយលះបង់ចោលនូវសំពត់សាដក ដែលប្រកបដោយទោស ៩ ប្រការ ក្នុងបណ្ណសាលានោះ ។ ព្រោះហេតុនោះ តថាគតលះបង់ចោលនូវសំពត់សាដក ដោយហេតុតែឃើញទោស ៩ ប្រការ ។ អដ្ឋសាលិនី និងជាតកដ្ឋកថា ។

១-ក្នុងគាថានេះ បាទគាថាថា *អដ្ឋទោសសមាកិណ្ណំ បជហិ បណ្ណសាលកំ* មានសេចក្តីថា តើសុមេធបណ្ឌិត លះបង់បានយ៉ាងដូចម្តេច ? បានឮមកថា សុមេធបណ្ឌិតនោះ កាលដោះសំពត់សាដកដែលមានសាច់ម៉ដ្ឋល្អចេញ ក៏កាន់យកសំពត់សម្បកឈើ មានពណ៌ដូចជាផ្កានទោង ដែលពាក់នៅលើស្នួរ រួចក៏ដណ្តប់សំពត់សម្បកឈើ មានពណ៌ដូចមាសមួយផ្ទាំងទៀត សង្កត់លើសំពត់ស្លៀកនោះ ធ្វើស្បែកខ្លាមានក្រចក ដែលមានសណ្ឋានដូចផ្កាបុន្នាគ(បុសនាគ)ឲ្យជាសំពត់នៅលើស្មាម្ខាង ហើយពាក់មណ្ឌលជដា ស៊កឃ្នៀបរឹងរបនឹងផ្នួងសក់ ដើម្បីកុំឲ្យញាប់ញ័រ បន្ទាប់មកតម្កល់

**ទាបិតំ រោបិតំ ធញ្ញំ    បជហឹ និរវសេសតោ**

**អនេកគុណសម្បន្នំ    បវត្តផលមាទយឹ ។**

*លះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិន*

*សេសសល់    កាន់យកផ្លែឈើ    ដែលជ្រុះឯង*

*បរិបូណ៌ដោយគុណច្រើនប្រការ ។*

---

ផ្តិលទឹក មានពណ៌ដូចជាកែវប្រពាឡទុកក្នុងសង្រែក ដូចបណ្តាញនៃកែវមុក្តា ហើយកាន់ជង់រែកដែលកោងក្នុងទី ៣ កន្លែង បំពាក់ផ្តិលទឹកទុកត្រង់ចុងម្ខាងនៃជង់រែកបំពាក់លើទំពក់និងឈើជើង ៣ ជាដើម ទុកត្រង់ចុងម្ខាងនៃជង់រែក ហើយរែកគ្រឿងបរិក្ខារដាក់លើស្មាកាន់ឈើច្រត់ដោយដៃស្តាំ ចេញអំពីបណ្ណសាលាចង្ក្រមទៅមក លើទីចង្ក្រមមានប្រវែងប្រមាណ ៦០ ហត្ថ សម្លឹងមើលភេទរបស់ខ្លួនហើយត្រិះរិះថា មនោរថរបស់អាត្មាអញដល់ទីបំផុតហើយ ការបព្វជ្ជារបស់អញស្អាតល្អហើយហ្ន៎! ក៏ជាធម្មតាការបព្វជ្ជានេះគឺជីវបុរសទាំងពួង មានព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធជាដើម ព្រះអង្គទ្រង់សរសើរហើយ. គ្រឿងចងរបស់គ្រហស្ថអាត្មាអញលះបានហើយ. អាត្មាអញកាលចេញបួសហើយបាននូវបព្វជ្ជាដ៏ខ្ពង់ខ្ពស់ អាត្មាអញនឹងធ្វើនូវសមណធម៌ អាត្មាអញនឹងបានសេចក្តីសុខដែលកើតអំពីមគ្គផល ។ លុះត្រិះរិះដូច្នេះហើយ ក៏កើតឧស្សាហៈ លើកសង្រែកបរិក្ខារចុះរួចអង្គុយចុះលើផ្ទាំងសិលា មានពណ៌ដូចសណ្តែកខៀវ ក្នុងកណ្តាលទីចង្ក្រម ដូចរូបបដិមាមាស ញ៉ាំងថ្ងៃឲ្យកន្លងទៅ លុះវេលាល្ងាច ក៏ចូលទៅក្នុងបណ្ណសាលា សឹងលើគ្រឿងលាត ដែលធ្វើដោយឈើ ត្រង់ចំហៀងគ្រែឫស្សីម្ខាង ឲ្យសរីរៈទទួលប៉ះពាល់អាកាស រួចហើយក៏ភ្ញាក់ឡើងក្នុងវេលាជិតភ្លឺ ពិចារណាដល់ការមករបស់ខ្លួនថា អាត្មាអញឃើញទោសក្នុងឃរាវាស ទើបលះបង់នូវភោគសម្បត្តិរាប់ប្រមាណមិនបាន និងយសដ៏ប្រសើរ ចូលទៅកាន់ព្រៃស្វែងរកនេក្ខម្មៈ. ចាប់ផ្តើមអំពីថ្ងៃនេះទៅ អាត្មាអញនឹងប្រព្រឹត្ត

តត្ថប្បធានំ បទហឹ   និសជ្ជដ្ឋានចង្កមេ

អព្ភន្តរម្ហិ សត្តាហេ   អភិញ្ញាពលបាបុណឹ ។[១]

តថាគតផ្គងព្យាយាម   ក្នុងអាស្រមបទនោះ

(ញុំាងយប់និងថ្ងៃឲ្យកន្លងទៅ) ក្នុងទីអង្គុយ ទីឈរ

និងទីចង្ក្រម   បានលុះអភិញ្ញាពលៈ   ក្នុងរវាង

៧ ថ្ងៃ ។

---

នូវខ្លួនដោយសេចក្ដីមិនប្រមាទ ព្រោះថា សត្វល្អិតគឺមិច្ឆាវិតក្កៈ រមែងទំពារស៊ីនូវអ្នកដែលប្រាសចាកសេចក្ដីស្ងប់ស្ងាត់(វិវេក)ហើយត្រាច់ទៅ ឥឡូវនេះ គួរតែអាត្មាអញពូន(ចម្រើន)សេចក្ដីស្ងប់ស្ងាត់ ដោយឃើញបលិពោធ(គ្រឿងកង្វល់) របស់យាវាសក្នុងការគ្រប់គ្រងផ្ទះ ហើយទើបចេញមក. ក៏បណ្ណសាលានេះជាទីញុំាងចិត្តឲ្យរីករាយ មានផ្ទៃរាបស្មើដែលត្បូងដោយរបង មានពណ៌ដូចផ្លៅទុំ ទាំងជញ្ជាំងក៏សស្អាត ដូចផែនប្រាក់ រីឯដំបូលមានពណ៌ដូចជើងព្រាប ចំណែករនាបគ្រែមានពណ៌ដូចគ្រឿងលាតដ៏វិចិត្រ ដែលជាទីអាស្រ័យនៅដ៏សុខស្រួល. ការដល់ព្រមដោយហេតុនៃផ្ទះរបស់អាត្មាអញ នឹងប្រាកដជាក្រៃលែងថែមទៀត ៗ លុះគិតពិចារណាមានប្រមាណប៉ុណ្ណេះហើយ ក៏ត្រួតពិនិត្យមើលនូវទោសទាំងឡាយ ទើបឃើញទោសនៃបណ្ណសាលា ៨ ប្រការ ៗ អដ្ឋសាលិទីនិងជាតកដ្ឋកថា ។

១-ព្រះគាថាទាំង ២ ក្នុងទំព័រ ២៧ និង២៨ ព្រះមានព្រះភាគទ្រង់សម្ដែងព្រោះហេតុព្រះអង្គឃើញគល់ឈើ ប្រកបដោយគុណទាំង ១០ ប្រការ ទើបពោលឡើងថា អាត្មាអញចូលទៅអាស្រ័យត្រង់គល់ឈើនេះ ៗ ព្រះមហាពោធិសត្វកំណត់នូវហេតុប៉ុណ្ណេះហើយស្លៀកឡើងក៏ចូលទៅកាន់ស្រុកដើម្បីភិក្ខា ៗ គ្រានោះ ពួកមនុស្សអ្នកនៅស្រុកដែលព្រះអង្គ

# ការកសាងផ្លូវ និងទទួលពាក្យព្យាករណ៍

លុះសុមេធតាបស បានបន្ទុះអភិញ្ញាពលៈ ក៏ញ៉ាំងកាលឲ្យប្រព្រឹត្តទៅ ដោយសេចក្ដីសុខ ដែលកើតពីសមាបត្តិ ។ ក្នុងកាលនោះ ព្រះសាស្ដាទ្រង់ព្រះនាមទីបង្ករ ស្ដេចឧបត្តិឡើងក្នុងលោក ក្នុងការបដិសន្ធិផង ប្រសូតផង ត្រាស់ដឹងផង និងការសម្ដែងនូវព្រះធម្មចក្រផង លោកធាតុទាំងមួយម៉ឺនកម្រើករញ្ជួយញាប់ញ័រ បុព្វនិមិត្តទាំង ៣២ ប្រការ ក៏ប្រាកដឡើង ។ សុមេធបណ្ឌិត ដោយហេតុតែញ៉ាំងកាលឲ្យកន្លងទៅ

---

ចូលទៅដល់បានថ្វាយនូវកិច្ចាដោយខ្ទីឃ្មាត ។ ព្រះមហាពោធិសត្វ លុះធ្វើកត្តកិច្ចស្រេចហើយ ក៏ត្រឡប់មកកាន់អាស្រមវិញ អង្គុយត្រិះរិះថា អាត្មាអញបួសដោយគិតថា អញនឹងមិនបានអាហារក៏មិនមែនដែរ ធម្មតា ដែលឈ្មោះថាអាហារដែលមានរសឆ្ងាញ់ រមែងញ៉ាំងសេចក្ដីស្រវឹងដោយមានៈ និងស្រវឹងថាជាបុរសឲ្យចម្រើនឡើង ក៏ឯទីបំផុតនៃសេចក្ដីទុក្ខដែលមានអាហារជាមូលរមែងមិនមាន បើដូច្នោះ អាត្មាអញ គប្បីលះបង់នូវអាហារកើតពីធញ្ញជាតិ ដែលគេព្រោះ គេដាំ បរិភោគតែផ្លែឈើដែលជ្រុះឯង ។ ចាប់ដើមអំពីកាលនោះមក ព្រះមហាពោធិសត្វធ្វើយ៉ាងនេះជាប់តគ្នាមិនដាច់ ផ្គងនូវសេចក្ដីព្យាយាមក៏បានបន្ទុះសមាបត្តិ ៨ និងអភិញ្ញា ៥ ក្នុងរវាង ៧ ថ្ងៃ ។ អដ្ឋសាលិនី ជាតកដ្ឋកថា ។

ដោយសេចក្ដីសុខ ដែលកើតអំពីសមាបត្តិ ទើបមិនបានព្រះ

សម្ដេង ទាំងមិនបានឃើញនូវនិមិត្តទាំងនោះ ។ ដោយហេតុ

នោះ ទើបត្រាស់ថា :

**៦៩៎ មេ សិទ្ធិបត្តស្ស ខសីភូតស្ស សាសនេ**

**ទីបង្ករោ នាម ជិនោ ឧប្បជ្ជិ លោកនាយកោ ។**

កាលតថាគត សម្រេចអភិញ្ញាហើយ ជាអ្នក

មានវសី ក្នុងសាសនានៃតាបស កាលនោះ

ព្រះជិនស្រី ព្រះនាមទីបង្ករ ជានាយកនៃលោក

ទ្រង់កើតឡើង ។

**ឧប្បជ្ជន្តេ ច ជាយន្តេ ពុជ្ឈន្តេ ធម្មទេសនេ**

**ចតុរោ និមិត្តេ នាទ្ទសំ ឈានរតិសមប្បិតោ ។**

កាលព្រះពុទ្ធចាប់បដិសន្ធិផង ប្រសូតផង

កាលត្រាស់ដឹងផង សម្ដែងធម្មចក្រផង តថាគត

ជាអ្នកផ្ដេកស្កប់ស្កល់ ដោយសេចក្ដីត្រេកអរ ក្នុងឈាន ប៉ុន្តែមិនបានឃើញនូវនិមិត្តទាំង ៤ ឡើយ ។

ក្នុងសម័យនោះ ព្រះទសពលព្រះនាមទីបង្ករ មានភិក្ខុសង្ឃជាព្រះខីណាស្រពប្រមាណ ៤ សែនអង្គចោមរោមជាបរិវារ ទ្រង់ស្ដេចទៅកាន់ជនបទចារិកតាមលំដាប់រហូតដល់រម្មកនគរ ព្រះអង្គក៏ប្រថាប់នៅក្នុងសុទស្សនមហាវិហារ ។ ពួកមហាជនអ្នកនៅក្នុងរម្មកនគរបានឮដំណឹងថា ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ, ប្រកាសនូវព្រះធម្មចក្រដ៏ប្រសើរ ស្ដេចមកដល់រម្មកនគរហើយ ឥឡូវព្រះអង្គគង់នៅក្នុងសុទស្សនមហាវិហារ ក៏នាំគ្នាកាន់យកនូវភេសជ្ជៈ មានសប្បិ(ទឹកដោះថ្លា) និងនវនីតៈ(ទឹកដោះខាប់)ជាដើម ព្រមទាំងគ្រឿងសក្ការៈទាំងឡាយ

មានសំពត់សម្រាប់ស្លៀកដណ្តប់ និងដៃកាន់នូវផ្កាកម្រង និងគ្រឿងក្រអូបជាដើម ចូលទៅត្រង់ទីណា ដែលជាកន្លែងនៃព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះសាស្តា បូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម រួចអង្គុយក្នុងទីដ៏សមគួរ ស្តាប់ធម្មទេសនា ។ លុះចប់ធម្មទេសនា ក៏និមន្តព្រះសម្មាសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃសូមឲ្យទទួលភត្តក្នុងថ្ងៃស្អែក ។ កាលបើដឹងថាព្រះអង្គទទួលនិមន្តហើយ ក៏នាំគ្នាថ្វាយបង្គំ ក្រោកចាកអាសនៈ ធ្វើប្រទក្សិណជៀសចេញទៅ ។ លុះដល់ព្រឹកឡើងថ្ងៃស្អែក ក៏នាំគ្នាត្រៀមមហាទាន តាក់តែងព្រះនគរ ជម្រះផ្លូវជាទីយាងមកនៃព្រះទសពល ក្នុងទីណា ដែលមានទឹកជ្រោះក៏យកដីមកចាក់បន្ថែម ដើម្បីឲ្យរាបស្មើ រោយរាយដីខ្សាច់ដែលមានពណ៌ដូចជាផ្ទាំងនៃប្រាក់ បាចសាចលាជ និងផ្កា

ឈើ លើកទង់ជ័យ ទង់ផ្កាលា និងសំពត់ទឹកចត់ ដែលមាន

ពណ៌ផ្សេង ៗ ដាក់តាំងដើមចេក និងក្អមទឹកពេញដោយ

ផ្កាឈើ តំរៀបជាជួរជង្រ្គៃគ្នា ។ គ្រានោះ សុមេធតាបស

ហោះអំពីអាស្រមបទរបស់ខ្លួន តាមផ្លូវអាកាស ខាងលើ

ពួកមហាជនទាំងនោះ ក្រឡេកមើលទៅឃើញមហាជន

កំពុងតែពេញចិត្ត ត្រេកអរ ស្រស់ស្រាយ រីករាយ ក៏គិតថា

តើមានហេតុដូម្តេចទៅហ្ន៎! រួចក៏ចុះអំពីអាកាស ឈរក្នុងទី

ដ៏សមគួរ ហើយសួរដល់មហាជន ក្នុងខណៈនោះថា

ម្នាលលោកអ្នកដ៏ចម្រើនទាំងឡាយ តើពួកលោកនាំគ្នាជម្រះ

ផ្លូវនេះ ដើម្បីអ្នកណា ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

**បច្ចន្តទេសវិសយេ និមន្តេត្វា តថាគតំ**

**តស្ស អាគមនំ មគ្គំ សោធេន្តិ តុដ្ឋមានសា ។**

ពួកមហាជន ក្នុងបច្ចន្តប្រទេស មានចិត្ត

ត្រេកអរ និមន្តព្រះតថាគត បាននាំគ្នាជម្រះផ្លូវ ជាទីមកនៃព្រះតថាគតនោះ ។

អហន្តេន សមយេន និក្ខមិត្វា សកស្សមា

ធុនន្តោ វាកចីរានិ គច្ឆាមិ អម្ពរេ តទា ។

វេទជាតំ ជនំ ទិស្វា តុដ្ឋហដ្ឋំ បមោទិតំ

ឱរោហិត្វាន គគនា មនុស្សេ បុច្ឆិ តាវទេ ។

តុដ្ឋហដ្ឋោ បមុទិតោ វេទជាតោ មហាជនោ

កស្ស សោធិយតី មគ្គោ អញ្ជសំ វដុមាយនំ ។

សម័យនោះឯង តថាគតចេញអំពីអាស្រម របស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះ ទៅឯអាកាស តថាគតឃើញជនកំពុងតែពេញចិត្ត ត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះអំពី អាកាសហើយសួរមនុស្សទាំងឡាយ ក្នុងខណៈ

នោះថា មហាជនគ្រេកអរ ស្រស់ស្រាយ រីករាយ

ពេញចិត្ត ជម្រះផ្លូវ គន្លង ប្រឡាយ ដើម្បី

អ្នកណា ។

ពួកមនុស្សទាំងនោះឆ្លើយថា បពិត្រសុមេធដ៏ចម្រើន លោកមិនជ្រាបទេឬថាព្រះទសពលព្រះនាមទីបង្ករ ព្រះអង្គ បន្ទុះនូវសម្ពោធិញ្ញាណហើយ ទ្រង់ប្រកាសនូវព្រះធម្មចក្រ ដ៏ប្រសើរ ស្ដេចចារិកមកដល់នគររបស់ពួកយើង ឥឡូវនេះ គង់អាស្រ័យនៅក្នុងសុទស្សនមហាវិហារ ពួកយើងនិមន្ត ព្រះមានព្រះភាគអង្គនោះ បានជានាំគ្នាជម្រះផ្លូវនេះ ដែលជាទី យាងមករបស់ព្រះអង្គ ។ សុមេធតាបស មានចិត្តត្រិះរិះថា សូម្បីត្រឹមតែពាក្យប្រកាសឡើងថា ព្រះពុទ្ធ ក៏រកបានដោយ កម្រក្នុងលោក ចាំបាច់និយាយថ្វីដល់ការកើតឡើងនៃព្រះពុទ្ធ នោះ ។ បើដូច្នោះ អាត្មាអញ ក៏នឹងរួមជម្រះផ្លូវថ្វាយ

ដល់ព្រះទសពល ជាមួយនឹងមនុស្សទាំងឡាយដែរ ។ សុមេធតាបស លុះគិតដូច្នេះហើយ ក៏ពោលទៅរកមនុស្សទាំងនោះថា ប្រសិនបើ លោកអ្នកដ៏ចម្រើនទាំងឡាយ ជម្រះផ្លូវនេះដើម្បីថ្វាយដល់ព្រះពុទ្ធ សូមឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវ ដើម្បីថ្វាយព្រះទសពល ជាមួយនឹងពួកលោកដែរ ។ ពួកមហាជន កាលបើសុមេធតាបស សូមការអនុញ្ញាតហើយ ក៏ឆ្លើយតបថា ប្រពៃហើយ ។ ពួកមហាជន ដោយយល់ឃើញថា សុមេធតាបស ជាអ្នកមានឫទ្ធិ ទើបកំណត់ត្រង់ទីគ្រលុក ដែលមានទឹកប្រោះឲ្យ ដោយពោលថា សូមលោកម្ចាស់ ជម្រះត្រង់ទីនេះចុះ ។ សុមេធតាបស ទទួលយកដោយបីតិសោមនស្ស ដែលមានព្រះពុទ្ធជាអារម្មណ៍ ហើយគិតថា បើអាត្មាអញ តាក់តែងជម្រះផ្លូវនេះដោយឫទ្ធិសោតក៏បាន

ប៉ុន្តែការជម្រះ ដោយឫទ្ធិយ៉ាងនេះ ចិត្តរបស់អាត្មាអញមិនត្រេកអរ រីករាយ ខ្លាំងក្លាឡើយ បើអីចឹងក្នុងថ្ងៃនេះ អាត្មាអញ នឹងជម្រះផ្លូវ ដោយកម្លាំងកាយតែប៉ុណ្ណោះ ។ លុះគិតដូច្នេះហើយ ក៏ជញ្ជូនដី យកមកចាក់បន្ថែម ត្រង់គ្រលុកនោះ ។ កាលផ្លូវ របស់សុមេធតាបសធ្វើនោះ មិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះទសពលព្រះនាមទីបង្ករ ស្តេចទ្រង់ដំណើរយាងយាស លើផ្ទាំងនៃមនោសិលា ដោយពុទ្ធលីលាដូចរាជសីហ៍ រកទីបំផុតមិនមាន មានភិក្ខុសង្ឃជាព្រះខីណាស្រពប្រមាណ ៤ សែនអង្គ សុទ្ធតែជាអ្នកបានអភិញ្ញា ៦ មានអានុភាពច្រើន ចោមរោមជាបរិវារ ស្តេចយាងមកដល់ផ្លូវ ដែលបានជម្រះតាក់តែងនោះ ។ ក្នុងគ្រានោះ ពួកទេវតាក៏បូជាដោយគ្រឿងក្រអូប និងផ្កាឈើ ព្រមទាំងប្រគំនូវតូរ្យតន្ត្រី ជាទិព្វទាំងឡាយ ។ ចំណែក

ពួកមនុស្ស ក៏បូជាដោយគ្រឿងក្រអូប និងផ្កាឈើទាំងឡាយ ជារបស់មនុស្ស ។ សុមេធតាបស បើកភ្នែកទាំងគូ សម្លឹងមើលនូវព្រះវរកាយ នៃព្រះទសពលស្តេចយាងមក ដែលមានព្រះរូបឆោម ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងលម្អដោយអនុព្យញ្ជនៈ ៨០ មានព្រះរស្មីផ្សាយចេញប្រមាណ ១ ព្យាម ដោយជុំវិញ ដែលមានព្រះឆព្វណ្ណរង្សី ធៀលធ្លាត់ដូចជាផ្លេកបន្ទោរ នាឰដ៏អាកាស មានពណ៌ដូចជាកែវមណី បែងចាំងចុះឡើងជាគូ ៗ, ក៏គិតថា ថ្ងៃនេះ អាត្មាអញ គប្បីបរិច្ចាគជីវិត ថ្វាយដល់ព្រះទសពល ព្រោះហេតុនោះ សូមព្រះមានព្រះភាគ កុំជាន់លើភក់ឡើយ ជាន់លើខ្នងរបស់អាត្មាអញចុះ សូមស្តេចមួយអន្លើដោយព្រះខីណាស្រពទាំង ៤ សែនអង្គ ហាក់ដូចជាទ្រង់ជាន់លើស្ពានកែវមណីចុះ ការមិនយាងជាន់លើភក់នោះ នឹង

ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អាត្មាអញ អស់កាលយូរ ។ កាលបើគិតយ៉ាងនេះហើយ ក៏រំសាយសក់ ក្រាលស្បែកខ្លា ជដា និងសំពត់សម្បកឈើ លើភក់ក្រាស់ពណ៌ខ្មៅ ហើយប្រាស់ខ្លួនដេកសន្ធឹងធ្វើជាស្ពានលើភក់នោះ ដូចជាស្ពាននៃផ្ទាំងកែវមណី ។ (១) ព្រោះហេតុនោះ ទើបត្រាស់ថា :

**តេ មេ បុដ្ឋា ទិយាកំសុ ពុទ្ធោ លោកេ អនុត្តរោ**

---

១-ក្នុងកាលនោះ មាននាងកញ្ញាម្នាក់ កើតក្នុងត្រកូលព្រាហ្មណ៍ ឈ្មោះសុមិត្តា កាន់យកផ្កាឧប្បល ៨ ក្តាប់ ចូលមកកាន់ទីប្រជុំជន ដើម្បីបូជាដល់ព្រះទសពលទីបង្ករ ។ លុះចូលមកដល់ ក៏បានឃើញសេចក្តីព្យាយាមប្រកបដោយផល របស់សុមេធបណ្ឌិត ក្នុងកណ្តាលនៃមហាជន ទើបញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតឡើង រួចថ្វាយផ្កាឧប្បល ៥ ក្តាប់ ដោយទុកខ្លួនឯងត្រឹមតែ ៣ ក្តាប់ប៉ុណ្ណោះ សម្រាប់បូជាដល់ព្រះសាស្តា ព្រះនាមទីបង្ករ ដោយពោលឡើងក្នុងកាលនោះថា :

បពិត្រឥសី ខ្ញុំមិនឃើញវត្ថុដទៃ ដែលគួរថ្វាយទេ ខ្ញុំសូមថ្វាយផ្កាទាំងឡាយដល់លោក ។ បពិត្រឥសី ផ្កា ៥ ក្តាប់នេះ ចូរមានដល់លោក ផ្កា ៣ ក្តាប់នេះ ចូរមានដល់ខ្ញុំ បពិត្រឥសី ផ្កាទាំងឡាយ ចូរជារបស់ស្មើគ្នា មួយអន្លើដោយឥសីនោះ ដើម្បីប្រយោជន៍ ដល់ពោធិញ្ញាណ របស់ព្រះអង្គ ។ សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ( យសោធរាថេរិយាបទាន ទី ៧ ) ។

ទីបង្ករោ នាម ជិនោ ឧប្បជ្ជិ លោកនាយកោ

តស្ស សោធិយតេ មគ្គោ អញ្ញាសំ ខជុមាយនំ ។

ពួកជនទាំងនោះ ដែលតថាគតសួរហើយ

ក៏ឆ្លើយប្រាប់ថា ព្រះពុទ្ធដ៏ប្រសើរ ក្នុងលោក

ជាព្រះជិនស្រី ព្រះនាមទីបង្ករ ជាលោកនាយក

ទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវ គន្លង

ប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ ។

ពុទ្ធោតិ មម សុត្វាន បីតិ ឧប្បជ្ជិ តាវទេ

ពុទ្ធោ ពុទ្ធោតិ កថយន្តោ សោមនស្សំ បវេទយឹ ។

បីតិកើតឡើងដល់តថាគត ក្នុងខណៈនោះ

ព្រោះតែឮពាក្យថាព្រះពុទ្ធ តថាគតទន្ទេញថា

ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ហើយក៏បាននូវ

សោមនស្ស ។

គគ្គ បត្វា ទិចិរន្តសី គុរដ្ឋា សំទិគ្គមានសោ

ឥធ ទីឋានិ រោបិស្សំ ខណោ វេ មា ឧបច្ចគា ។

តថាគត ឋិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្ដុះពូជ កុសល ក្នុងបុញ្ញក្ខេត្តនេះ កុំឲ្យខណៈកន្លងទៅទទេឡើយ ។

យទិ ពុទ្ធស្ស សោធេថ ឯកោកាសំ ទទាថ មេ

អហំបិ សោធយិស្សាមិ អញ្ជសំ វដុមាយនំ ។

(លុះគិតដូច្នេះហើយ ក៏និយាយទៅរកមហាជនថា) បើអ្នកទាំងឡាយ ជម្រះផ្លូវ ថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយ ដល់អាត្មាផង អាត្មានឹងជម្រះផ្លូវប្រឡាយដែរ ។

អធិសុ រេ មរមោការេ រសោរេតាំ អញ្ញូសំ គធា
ពុទ្ធោ ពុទ្ធោតិ ចិន្តេន្តោ មគ្គំ រសោចមហន្តធា ។

កាលនោះ ពួកជនទាំងនោះ ក៏ឲ្យឱកាសមួយ
ដល់តថាគត ដើម្បីជម្រះផ្លូវ តថាគតគិតថា
ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ជម្រះផ្លូវបណ្ដើរ
ក្នុងឱកាសនោះ ។

អនិដ្ឋិតេ មរមោការេ ទីបង្ករោ មហាមុនិ
ចតូហិ សតសហស្សេហិ ឆឡភិញ្ញេហិ តាទិហិ
ខីណាសវេហិ វិមលេហិ បដិបជ្ជិ អញ្ជសំ ជិនោ ។

កាលដែលឱកាស(ផ្លូវ) របស់តថាគត ធ្វើ
មិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះជិនស្រី
ជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្ដេចយាងមក
តាមផ្លូវជាមួយនឹងព្រះខីណាស្រព ៤ សែនរូប

សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិបុគ្គល

ប្រាសចាកមន្ទិល ។

បច្ចុគ្គមនា ខត្តិ ខជ្ជន្តិ ភេរិយោ ពហូ

អាមោទិតា នរមរូ សាធុការំ បវត្តយុំ ។

ការក្រោកទទួល(ព្រះសាស្តា) ក៏ប្រព្រឹត្តទៅ

ស្គរទាំងឡាយជាច្រើនក៏លាន់ឮឡើងគគ្រឹកគគ្រេង

ពួកមនុស្ស និងទេវតា ក៏ត្រេកអរ ញុំាងសាធុការ

ឲ្យប្រព្រឹត្តទៅ ។

ទេវា មនុស្សេ បស្សន្តិ មនុស្សា បស្សន្តិ ទេវតា

ឧភោបិ តេ បញ្ជលិកា អនុយន្តិ តថាគតំ ។

ពួកទេវតាឃើញពួកមនុស្ស ឯពួកមនុស្ស

ក៏ឃើញពួកទេវតា ទេវតានិងមនុស្សទាំងពីរពួក

នេះ បានផ្គងអញ្ជលី ដើរដង្ហែព្រះតថាគត ។

ទេវា និព្វេហិ គុរិយេហិ មនុស្សា មានុសកេហិ ច

ឧភោបិ តេ វជ្ជយន្តា អនុយន្តិ តថាគតំ ។

ពួកទេវតា ប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្ស ក៏ប្រគំតូរ្យតន្ត្រីជារបស់មនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។

ទិព្វំ មន្ទារវំ បុប្ផំ បទុមំ បារិឆត្តកំ

ទិសោទិសំ ឱកិរន្តិ អាកាសេ នភគាមរូ ។

ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្ស ផ្កាឈូក ផ្កាបារិឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាសអំពីទិសតូចទិសធំ ។

ទិព្វំ ចន្ទនចុណ្ណញ្ច វរគន្ធញ្ច កេវលំ

ទិសោទិសំ ឱកិរន្តិ អាកាសេ នភគាមរូ ។

ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏ពោយ

រាយលម្អិតខ្លឹមចន្ទន៍ទិព្យផង គ្រឿងក្រអូបដ៏ប្រសើរ

ទាំងអស់ផង អំពីទិសតូចទិសធំឰដ៏អាកាស ។

ចម្បកំ សលឡំ នីបំ នាគបុន្នាគកេតកំ

ឥសោគិសំ ឱកិរន្តិ ភូមិតលគតា នរា ។

ពួកមនុស្សដែលឋិតនៅលើផែនដី ក៏ពោយ

រាយផ្កាចម្បា ផ្កាស្រស់ ផ្កាក្តម ផ្កាខ្ទឹង ផ្កាបុសនាគ,

និងផ្កាកាកេស អំពីទិសតូចទិសធំ ។

កេសេ មុញ្ចិត្វាហំ តត្ថ វាកចីរំ ច ចម្មកំ

កលលេ បត្ថរិត្វាន អវកុជ្ជោ និបជ្ជហំ ។

អក្កមិត្វាន មំ ពុទ្ធោ សហ សិស្សេហិ គច្ឆតុ

មា នំ កលលំ អក្កមិត្ថ ហិតាយ មេ ភវិស្សតិ ។

តថាគត រំសាយសក់ ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ(អធិដ្ឋានថា) សូមព្រះពុទ្ធព្រមទាំងពួកសិស្ស ជាន់អាត្មាអញ យាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ។

សុមេធតាបស ដេកលើភក់នោះឯង បើកភ្នែកទាំងគូសម្លឹងឃើញពុទ្ធសិរី នៃព្រះទសពលទីបង្ករ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើអាត្មាអញ ប្រាថ្នាដុតនូវកិលេសទាំងពួងឲ្យអស់ នឹងបានជានវកសង្ឃចូលទៅកាន់រម្មកនគរក៏បាន តែប្រយោជន៍អ្វី ដែលអាត្មាអញដុតកិលេស ដោយភេទដែលគេមិនស្គាល់ ហើយបន្ទះនូវនិព្វាននោះ បើដូច្នោះអាត្មាអញ គប្បីបានត្រាស់ដឹងនូវអភិសម្ពោធិញ្ញាណដ៏ឧត្តម

ដូចព្រះទសពលទីបង្ករដែរ ហើយឡើងកាន់ធម្មនាវា ចម្លងមហាជន ចាកសង្សារសាគរ សឹមបរិនិព្វានដោយខ្លួនឯងក្នុងកាលជាខាងក្រោយ ការធ្វើយ៉ាងនេះ ទើបសមគួរដល់អាត្មាអញ ។ បន្ទាប់ពីបានគិតយ៉ាងនោះមក ក៏ប្រកបព្រមដោយធម្មសមោធាន ៨(*) ប្រការ ដែលជាទីតាំងញ៉ាំងសេចក្ដីប្រាថ្នាដ៏ក្រៃលែង ដើម្បីកិរិយាត្រាស់ជាព្រះពុទ្ធឲ្យសម្រេចរួចក៏ដេកចុះ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

**បត្ថយិ និបន្នស្ស ឯវំ មេ អាសិ ចេតសោ**

**ឥច្ឆមានោ អហំ អជ្ជ កិលេសេ ឈាបយេ មម ។**

កាលតថាគតដេកលើផែនដី ក៏មានសេចក្ដីត្រិះរិះដោយចិត្តយ៉ាងនេះថា បើអាត្មាអញប្រាថ្នាដុតកិលេសទាំងឡាយ របស់អញ ក្នុងថ្ងៃនេះក៏បាន ។

**កឹ មេ អញ្ញាតវេសេន ធម្មំ សច្ឆិកតេនិធ**

**សព្វញ្ញុតំ បាបុណិត្វា មុត្តោ មោចេ សទេវកេ ។**

តែជាប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់
នូវធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ
អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួច
ស្រឡះចាកកិលេស ញុំាងលោក ព្រមទាំង
ទេវលោក ឲ្យរួចរំដោះ(ចាកសង្សារ) ៗ

**កឹ មេ ឯកេន តិណ្ណេន បុរិសេន ថាមទស្សិនា**

**សព្វញ្ញុតំ បាបុណិត្វា សន្តារេស្សំ សទេវកេ ។**

ប្រយោជន៍អ្វី អាត្មាអញជាបុរស សម្តែង
កម្លាំងថ្លងទៅម្នាក់ឯង អាត្មាអញ គួរដល់នូវ
សព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក ព្រមទាំង
ទេវលោក ៗ

ឥមិនា មេ អធិការេន កតេន បុរិសុត្តមេ

សព្វញ្ញុតំ បាបុណាមិ តារេមិ ជនតំ ពហុំ ។

អាត្មាអញ នឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។

សំសារសោតំ ឆិន្ទិត្វា វិទ្ធំសេត្វា តយោ ភវេ

ធម្មនាវំ សមារុយ្ហ សន្តារេស្សំ សទេវកេ ។

តថាគត នឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើងជិះលើនាវាគឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោក ។

ចំណែក ព្រះមានព្រះភាគព្រះនាមទីបង្ករ កាលបើស្តេចយាងផុតភក់នោះហើយ ទ្រង់ប្រថាប់ឈរក្បែរសីសៈរបស់សុមេធតាបស ទ្រង់សម្លឹងមើលដោយព្រះនេត្រទាំងគូ

ដែលបរិបូណ៌ ដោយបសាទមានពណ៌ ៥ ប្រការ បីដូចជាបើកនូវសីហបញ្ជរកែវមណី ឃើញនូវសុមេធតាបសដេកលើភក់ ក៏មានព្រះតម្រិះថា តាបសនេះធ្វើនូវអភិនីហារដើម្បីត្រាស់ដឹងជាព្រះពុទ្ធ តើសេចក្ដីប្រាថ្នារបស់តាបសនេះបានសម្រេចឬហ្ន៎! លុះមានព្រះតម្រិះយ៉ាងនេះហើយ ព្រះអង្គទើបបញ្ជូននូវអនាគតំសញ្ញាណពិចារណាមើល ក៏ជ្រាបបានថា នៅប្រមាណ ៤ អសង្ខេយ្យ និង ១ សែនកប្បទៀត រាប់អំពីកប្បនេះទៅ តាបសនេះ នឹងត្រាស់ជាព្រះពុទ្ធព្រះនាមគោតម ។ ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមទីបង្ករ ទ្រង់ប្រថាប់ឈរព្យាករណ៍ សុមេធតាបស ត្រង់កណ្ដាលនៃបរិស័ទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលនូវតាបស ដែលកំពុងដេកលើភក់នេះ មានតបៈដ៏ខ្ពង់ខ្ពស់ ។ ភិក្ខុទាំងឡាយ ក្រាបទូលថាឃើញហើយព្រះអង្គ ។

លុះភិក្ខុទាំងឡាយ ក្រាបទូលហើយ ព្រះអង្គក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តាបសនេះធ្វើនូវអធិការដើម្បីត្រាស់ដឹងជាព្រះពុទ្ធ ទើបដេកចុះលើភក់ សេចក្ដីប្រាថ្នារបស់តាបសនេះនឹងបានសម្រេច, ក្នុងទីបំផុតនៃ ៤ អសង្ខេយ្យ និង ១ សែនកប្បរាប់អំពីកប្បនេះទៅ តាបសនេះ នឹងត្រាស់ជាព្រះពុទ្ធព្រះនាមថាគោតម ។ ព្រះនគរជាលំនៅរបស់ព្រះពុទ្ធនោះឈ្មោះថា កបិលវត្ថុ ព្រះមាតាព្រះនាមមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ មានភិក្ខុឈ្មោះឧបតិស្សៈ និងកោលិតៈជាអគ្គសាវក ភិក្ខុឈ្មោះអានន្ទជាពុទ្ធុបដ្ឋាក មានភិក្ខុនីឈ្មោះខេមា និងឧប្បលវណ្ណា ជាអគ្គសាវិកា, វេលាដែលតាបសនេះ មានញាណចាស់ក្លា នឹងចេញសាងមហាភិនេ-ស្រ្កម ធ្វើទុក្ករកិរិយា បានទទួលមធុបាយាស ដែលនាងសុជាតាថ្វាយទៀបគល់អជបាលនិគ្រោធ យកទៅសោយ

ត្រង់ផ្នែរស៊ីងនេរញ្ជរា រួចចូលទៅកាន់ពោធិមណ្ឌល នឹងបាន

ត្រាស់ជាព្រះពុទ្ធទៀបគល់អស្សត្ថព្រឹក្ស ។ ព្រោះហេតុនោះ

ទើបត្រាស់ថា :

**ទីបង្ករោ លោកវិទូ អហុតីនំ បដិគ្គហោ**

**ឧស្សីសកេ មំ ឋត្វាន ឥទំ វចនមព្រវិ ។**

**បស្សថ ឥមំ តាបសំ ជដិលំ ឧគ្គតាបនំ**

**អបរិមេយ្យេ ឥតោ កប្បេ ពុទ្ធោ លោកេ ភវិស្សតិ ។**

ព្រះពុទ្ធ ព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់

នូវលោក ទ្រង់គួរទទួលគ្រឿងបូជាទាំងឡាយ

ទ្រង់ឈរក្បែរសីសៈរបស់តថាគត ត្រាស់ពាក្យ

នេះថា (ម្នាលភិក្ខុទាំងឡាយ) អ្នកទាំងឡាយ

ចូរមើលតាបសនេះ ជាជដិលមានតបៈដ៏ខ្ពង់ខ្ពស់

តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងលោក

ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ។

អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

សត្វនេះ នឹងចេញចាកក្រុងឈ្មោះកបិលវត្ថុ
ជាទីរីកកាយ តម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។

អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។

សត្វនេះ អង្គុយទៀបគល់អជបាលព្រឹក្ស
ទទួលបាយាស ដែលនាងសុជាតាថ្វាយក្នុងទីនោះ
នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។

នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។

តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ

អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

ព្រះជិនស្រីនោះ បានទទួលបាយាសទៀប ធ្វើស៊ើងនេរញ្ជរាហើយ នឹងត្រឡប់មកតាមផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ(អង្គុយ) ទៀបគល់ ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបានត្រាស់ដឹងនូវ អនុត្តរសម្មោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ៕

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ

បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។

កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា

អនាសវា វីតរាគា សន្តចិត្តា សមាហិតា

អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ព្រះជនិកាមាតា របស់តាបសនោះ នឹងមាន

នាមថា ព្រះនាងមាយាទេវី ព្រះបិតាព្រះនាម

សុទ្ធោទនៈ ឯតាបសនេះ នឹងមានឈ្មោះថា

ព្រះគោតម អគ្គសាវកទាំងពីររូបគឺ កោលិតៈ ១

ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាក

រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជា

ឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។

**ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា**

**អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។**

អគ្គសាវិកាពីររូបគឺ នាងខេមា ១ ឧប្បល-

វណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ

មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។

**ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ**

**ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។**

ឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគ

នោះ ហៅថាអស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាក

ដ៏ប្រសើរពីររូប គឺ ចិត្តៈ ១ ហត្ថាឡវកៈ ១ ។

**នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា**

**អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។**

នាងនន្ទមាតា និងនាងឧត្តរា ជាឧបដ្ឋាយិកា

ដ៏ប្រសើរ ព្រះគោតមមានយសនោះ មានព្រះជន្ម

១០០ វស្សា ។

សុមេធតាបស កាលបើបានស្តាប់ពាក្យព្យាករណ៍

អំពីសំណាក់នៃព្រះទសពលព្រះនាមទីបង្ករហើយ ក៏កើត

សេចក្តីសោមនស្ស រីករាយ ដោយគិតថា សេចក្តីប្រាថ្នា

របស់អាត្មាអញ នឹងបានសម្រេចដោយពិតប្រាកដ ។ ពួក

មហាជន លុះឮពាក្យព្យាករណ៍ របស់ព្រះទសពលព្រះនាម

ទីបង្ករ ក៏នាំគ្នាត្រេកអរ រីករាយថា សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ហើយក៏គិតដោយចិត្តថា ជាធម្មតា បុរសកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ តែងកាន់យក កំពង់ខាងក្រោម យ៉ាងណា ពួកយើងទាំងអស់គ្នា កាល មិនបានសម្រេចមគ្គផល ក្នុងសាសនានៃព្រះទសពលទីបង្ករ នេះទេ ក្នុងកាលជាអនាគត សុមេធតាបសនេះ ត្រាស់ជា ព្រះពុទ្ធ ពួកយើងគង់នឹងធ្វើឲ្យជាក់ច្បាស់មគ្គផល ក្នុងទី ចំពោះព្រះភក្ត្រ នៃសុមេធតាបសនេះ ដែលបានត្រាស់ជា ព្រះពុទ្ធមិនខាន ក៏យ៉ាងនោះដែរ ។ សូម្បីព្រះទសពលទីបង្ករ ទ្រង់សរសើរព្រះបរមពោធិសត្វ និងបូជាដោយផ្កាឈើ ៨ ក្តាប់ រួចធ្វើប្រទក្សិណាស្តេចចេញទៅ ។ ចំណែកឯ ព្រះខីណាស្រពទាំង ៤ សែនអង្គ ក៏បូជាព្រះបរមពោធិសត្វ ដោយគ្រឿងក្រអូប និងផ្កាកម្រង ហើយធ្វើប្រទក្សិណា

ជៀសចេញទៅ ។

គ្រានោះ កាលព្រះមានព្រះភាគព្រះនាមទីបង្ករ ទ្រង់ញ៉ាំងនូវប្រទីប គឺការត្រាស់ដឹងលោកទាំងពួង ដែលមានកិត្តិសព្ទ ជាព្រះខីណាស្រពហែហម, ពួកជនអ្នករម្មកនគរបូជា, ទេវតាទាំងឡាយថ្វាយបង្គំហើយ ស្ដេចពុទ្ធដំណើរទៅដូចជាកំពូលនៃភ្នំមាសដ៏ប្រសើរ បែងចាំងរស្មីត្រង់កណ្ដាលសន្និយា ។ ក្នុងកាលដែលទ្រង់ធ្វើដំណើរទៅនោះ ស្ដេចយាងតាមផ្លូវ ដែលអ្នករម្មកនគរតាក់តែងហើយ ដោយសម្ដែងឫទ្ធិច្រើនប្រភេទ រួចក៏ចូលទៅកាន់រម្មកនគរដែលជាទីគួរអភិរម្យ, សាយភាយដោយក្លិនផ្កាឈើក្រអូបនានា ដូចជាផង់ធូលីដ៏គួរឲ្យរីករាយ, លើកទង់ជ្វាលាខ្វាត់ខ្វែង មានពួកកមរដែលជាប់ចិត្តក្នុងក្លិន ហោះហើរក្រឡឹងជុំវិញ, ផ្ទៃមេឃស្រអាប់ដោយផ្សែងធូប ដូចជាទេវនគរ ។ ព្រះទសពល

ទីបង្ករ លុះស្តេចយាងទៅដល់ហើយ ក៏គង់លើអាសនៈដ៏សមគួរដែលគេក្រាលថ្វាយ ដូចជាព្រះចន្ទ្រនាសរទកាលរះឡើងលើកំពូលភ្នំយុគន្ធរ ពុំនោះសោតដូចជាព្រះទិនកររះឡើង កម្ចាត់នូវភាពងងឹត ញុំាងផ្កាបទុមឲ្យរីកឡើង ។ ចំណែកភិក្ខុសង្ឃ ក៏គង់លើអាសនៈ ដែលសមគួរដល់ខ្លួន ៗ តាមលំដាប់ ។ រីឯឧបាសកអ្នករម្មកនគរ ដែលដល់ព្រមដោយគុណមានសទ្ធាជាដើម ក៏នាំគ្នាថ្វាយទានមានខាទនីយៈជាដើម ដែលសម្បូរដោយពណ៌ ក្លិន និងឱជារសមិនមានទានដទៃស្មើ ជាហេតុនាំមកនូវសេចក្តីសុខ ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។

គ្រានោះ ព្រះបរមពោធិសត្វ បានស្តាប់ពាក្យព្យាករណ៍អំពីសំណាក់ព្រះទសពលទីបង្ករ ក៏សម្គាល់ភាវៈជាព្រះពុទ្ធ ដូចជានៅក្នុងកណ្តាប់ដៃរបស់ខ្លួន ដោយសន្និដ្ឋាន

ថា អាត្មាអញ មុខជានឹងបានត្រាស់ជាព្រះពុទ្ធយ៉ាងពិត ប្រាកដ ។ លុះពួកអ្នករម្មកនគរត្រឡប់ទៅវិញអស់ហើយ ក៏ក្រោកចាកភក់ ពិចារណាស្ទាបស្ទង់រកបារមីទាំងឡាយ ទើបអង្គុយតាំងសមាធិ លើគំនរនៃផ្កាឈើ ។ កាលបើ ព្រះមហាសត្វអង្គុយយ៉ាងនោះ ទេវតាទាំងមួយម៉ឺនចក្រវាឡ ក៏ថ្វាយសាធុការ ដោយពោលថា បពិត្រសុមេធតាបស ដ៏ចម្រើន ព្រះពោធិសត្វទាំងឡាយអំពីបូរាណ អង្គុយតាំង សមាធិ ដោយគិតថា អាត្មាអញនឹងជ្រើសរើសរកបារមី ទាំងឡាយ បុព្វនិមិត្តទាំងឡាយណា រមែងប្រាកដក្នុងកាល មុន បុព្វនិមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបាន ត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ពួកយើងដឹងនូវសេចក្តីនេះ ថា បើបុព្វនិមិត្តទាំងនេះប្រាកដដល់បុគ្គលណា បុគ្គលនោះ នឹងបានត្រាស់ជាព្រះពុទ្ធ ចំពោះខ្លួនឯងតែប៉ុណ្ណោះ ព្រោះ

ហេតុនោះ សូមលោកចូរផ្គងឡើង នូវសេចក្ដីព្យាយាមឲ្យមាំមួន ហើយបានសរសើរព្រះពោធិសត្វដោយប្រការផ្សេង ៗ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធពីជង្កុរោ អយំ ។

ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាករណ៍របស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយ ដោយគិតថា សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ

អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

សម្លេងហៅទាំងឡាយ ក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោកទាំងមួយម៉ឺនលោកធាតុ ទះដៃផង ស្រែកផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ។

យថា មនុស្សា នទី តរន្តា បដិតិត្ថំ វិរជ្ឈិយ

ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទី ។

ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ

អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

ពួកមនុស្ស កាលថ្វាយស្ទឹង បើឃ្វាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោមក៏ឈ្មោះថាថ្វាយស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្វាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះកក្រ្កនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។

ទីបង្ករោ លោកវិទូ អាហុតីនំ បដិគ្គហោ
មម កម្មំ បកិត្តេត្វា ទក្ខិណបាទមុទ្ធរិ ។

ព្រះពុទ្ធទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរ អំពើរបស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ ។

យេ តត្ថ អាសុំ ជិនបុត្តា សព្វេ បទក្ខិណមកំសុ មំ
ទេវា មនុស្សា អសុរា យក្ខា អភិវាទេត្វាន បក្កមុំ ។

សាវកទាំងឡាយណា ជាបុត្រនៃព្រះជិនស្រី

ក្នុងទីនោះ ពួកសាវកទាំងនោះ ក៏ធ្វើប្រទក្សិណ

តថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ

ពួកយក្ស ក៏ក្រាបថ្វាយបង្គំតថាគត ហើយជៀស

ចេញទៅ ។

ឧស្សន្នំ មេ អតិក្កន្តេ សសង្ឃេ លោកនាយកេ

សយនា វុដ្ឋហិត្វាន បល្លង្កំ អាភុជឹ តទា ។

កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ

កន្លងនូវការឃើញ របស់តថាគតទៅ តថាគត

ក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ។

សុខេន សុខិតោ ហោមិ បាមោជ្ជេន បមោទិតោ

បីតិយា ច អភិស្សន្នោ បល្លង្កំ អាភុជឹ តទា ។

តថាគត ជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខ រីករាយដោយបាមោជ្ជៈ ផ្សព្វផ្សាយដោយបីតិ អង្គុយពែនភ្នែន ក្នុងកាលនោះ ។

**បល្លង្កេន និសីទិត្វា ឯទំ ចិន្តេសិហំ តទា**

**ខសីភូតោ អហំ ឈានេ អភិញ្ញាបារមិង្គតោ ។**

តថាគត អង្គុយពែនភ្នែន គិតយ៉ាងនេះក្នុងកាលនោះថា អាត្មាអញ ជាអ្នកស្ទាត់ក្នុងឈានដល់នូវត្រើយនៃអភិញ្ញា ។

**សហស្សិយម្ហិ លោកម្ហិ ឥសយោ នត្ថិ មេ សមា**

**អសមោ ឥទ្ធិធម្មេសុ អលភឹ ឦទិសំ សុខំ ។**

ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសីស្មើដោយអាត្មាអញឡើយ អាត្មាអញ ឥតមាន

បុគ្គលស្មើ ក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវ
សេចក្តីសុខបែបនេះ ។

**បល្លង្កាភុជនេ មយ្ហំ ទសសហស្សាធិវាសិនោ**
**មហានាទំ បវត្តេសុំ ធុវំ ពុទ្ធោ ភវិស្សសិ ។**

ក្នុងកាលដែលតថាគត អង្គុយពែនភ្នែនគិត
យ៉ាងនេះ ពួកមហាព្រហ្ម ដែលនៅអាស្រ័យក្នុង
លោកធាតុមួយម៉ឺន ក៏ញ៉ាំងសម្លេងខ្លាំងឲ្យលាន់ឮ
ថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

**យា បុព្វេ ពោធិសត្តានំ បល្លង្កវរមាភុជេ**
**និមិត្តានិ បទិស្សន្តិ តានិ អជ្ជ បទិស្សរេ ។**

និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែន
នៃពោធិសត្វទាំងឡាយ ប្រាកដក្នុងកាលមុន
និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ។

សីតំ ព្យាបគតំ ហោតិ ឧណ្ហញ្ច ឧបសម្មតិ

តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់

និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបាន

ត្រាស់ជាព្រះពុទ្ធប្រាកដ ។

ទសសហស្សី លោកធាតុ និស្សទ្ទា ហោតិ និរាកុលា

តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសម្លេង

ឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ

លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

មហាវាតា ន វាយន្តិ ន សន្ទន្តិ សវន្តិយោ

តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

ខ្យល់ធំទាំងឡាយក៏ឈប់បក់ ស្ទឹងទាំងឡាយ

ក៏ឈប់ហូរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ

លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

ថលជា ជលជា បុប្ផា សព្វេ បុប្ផន្តិ តាវទេ

តេបជ្ជ បុប្ផិតា សព្វេ ធុវំ ពុទ្ធោ ភវិស្សសិ ។

ផ្កាទាំងពួង ដែលកើតលើគោក កើតក្នុងទឹក

ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញ

ផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ ។

លតា វា យទិវា រុក្ខា ផលំ ធារេន្តិ តាវទេ

តេបជ្ជ ផលិតា សព្វេ ធុវំ ពុទ្ធោ ភវិស្សសិ ។

វល្លិទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់

នូវផ្លែ ក្នុងខណៈនោះ វល្លិនិងឈើទាំងអស់នោះ

ក៏បរិបូណ៌ផ្ទៃក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជា

ព្រះពុទ្ធប្រាកដ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា រតនា ជោតន្តិ តាវទេ**

**តេបជ្ជ រតនា ជោតន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

កែវទាំងឡាយ ដែលឋិតនៅពួជ៏អាកាសក្តី

ឋិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ

កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបាន

ត្រាស់ជាព្រះពុទ្ធប្រាកដ ។

**មានុស្សកា ច ទិព្វា ច តុរិយា វជ្ជន្តិ តាវទេ**

**តេបជ្ជុភោ អភិរវន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស

និងជាទិព្វ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រី

ទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹង

បានត្រាស់ជាព្រះពុទ្ធប្រាកដ ។

**វិចិត្តបុប្ផា គគនា អភិវស្សន្តិ តាវទេ**

**តេបិ អជ្ជ បវិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាស ក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

**មហាសមុទ្ទោ អាភុជតិ ទសសហស្សី បកម្បតិ**

**តេបជ្ជុភោ អភិរវន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

មហាសមុទ្រ ក៏ស្រែកចុះ លោកធាតុទាំងមួយម៉ឺន ក៏ញាប់ញ័រក្នុងខណៈនោះ មហាសមុទ្រនិងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

**និរយេ ទសសហស្សា អគ្គី និព្វន្តិ តាវទេ**

តេជ្ជ និព្វុតា អគ្គី    ធុវំ ពុទ្ធោ ភវិស្សសិ ។

ភ្លើងក្នុងនរកទាំងមួយម៉ឺន ក៏រលត់ក្នុងខណៈ
នោះ ភ្លើងទាំងនោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹង
បានត្រាស់ជាព្រះពុទ្ធប្រាកដ ។

វិមលោ ហោតិ សុរិយោ សព្វា ទិស្សន្តិ តារកា
តេបិ អជ្ជ បទិស្សន្តិ    ធុវំ ពុទ្ធោ ភវិស្សសិ ។

ព្រះអាទិត្យប្រាសចាកមន្ទិល ផ្កាយទាំងពួង
ក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះ ក៏បាន
ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ
ប្រាកដ ។

អនោវុដ្ឋេន ឧទកំ    មហិយា ឧព្ភិជ្ជិ តាវទេ
តំបជ្ជុព្ភិជ្ជតេ មហិយា    ធុវំ ពុទ្ធោ ភវិស្សសិ ។

ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើ

ផែនដី ក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដី

ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

**តារាគណា វិរោចន្តិ នក្ខត្តា គគនមណ្ឌលេ**

**វិសាខា ចន្ទិមាយុត្តា ធុវំ ពុទ្ធោ ភវិស្សសិ ។**

ពួកផ្កាយទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្តឫក្ស

ទាំងឡាយ ប្រកបដោយព្រះចន្ទ្រខែវិសាខ (ក៏រុង

រឿង) ក្នុងមណ្ឌលនៃអាកាស លោកនឹងបាន

ត្រាស់ជាព្រះពុទ្ធប្រាកដ ។

**វិលាសយា ទរីសយា និក្ខមន្តិ សកាសយា**

**តេបជ្ជ អាសយា ឆុទ្ធា ធុវំ ពុទ្ធោ ភវិស្សសិ ។**

ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេក

ក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វ

ទាំងអស់នោះ ក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ

លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

ន ហោតិ អរតិ សត្តានំ សន្តុដ្ឋា ហោន្តិ តាវទេ

តេបជ្ជ សពេ្វ សន្តុដ្ឋា ធុវំ ពុទ្ធោ ភវិស្សសិ ។

សេចក្តីអផ្សុក មិនមានដល់សត្វទាំងឡាយ

សត្វទាំងឡាយជាអ្នកត្រេកអរ ក្នុងខណៈនោះ

ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ

លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

រោគា តទូបសម្មន្តិ ឱយច្ឆា ច វិនស្សតិ

តានិបជ្ជ បនិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

រោគទាំងឡាយដ៏ស្រាល ៗ ក៏ស្ងប់រម្ងាប់ទៅ

ទាំងសេចក្តីស្រេកឃ្លាន ក៏វិនាសទៅ ការស្ងប់

រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះ

ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ ។

រាគោ តថា តនុ ហោតិ ទោសោ មោហោ ចិនស្សតិ

គេបង្គ ចិគតា សព្វេ ធុវំ ពុទ្ធោ ភវិស្សសិ ។

រាគក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ

ក៏បាត់បង់ទៅ ក្នុងកាលនោះ រាគនិងកិលេស

ទាំងអស់នោះ ក៏ប្រាសចេញទៅក្នុងថ្ងៃនេះ លោក

នឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

ភយំ តថា ន ភវតិ អជ្ជេបតំ បនិស្សតិ

តេន លិង្គេន ជានាម ធុវំ ពុទ្ធោ ភវិស្សសិ ។

ឯភ័យមិនមាន ក្នុងកាលនោះ ការមិនមាន

ភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ

ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ ។

រថោ នុធំសតិ ឧធំ អច្ចុបេតំ បធិស្សតិ

តេន លិខេន ជានាម ធុវំ ពុទ្ធោ ភវិស្សសិ ។

ធូលី ក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយ

ធូលី ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើប

ពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ ។

អនិដ្ឋគន្ធោ បក្កមតិ ទិព្វគន្ធោ បវាយតិ

សោបជ្ជ វាយតិ គន្ធោ ធុវំ ពុទ្ធោ ភវិស្សសិ ។

ក្លិនស្អុយ ក៏ផាត់ចេញ ក្លិនទិព្វ ក៏ផ្សាយទៅ

ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោក

នឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

សព្វេ ទេវា បទិស្សន្តិ ឋរេបត្វា ច អរូបិនោ

តេបជ្ជ សព្វេ ទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្ម

ចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះ

ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ ។

យាវតា និរយា នាម សព្វេ ទិស្សន្តិ តាវទេ

តេបជ្ជ សព្វេ ទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដ

ក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯង ក៏

ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ ។

កុដា កវាដា សេលា ច ន ហោន្តាវរណា តទា

អាកាសភូតា តេបជ្ជ ធុវំ ពុទ្ធោ ភវិស្សសិ ។

ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរាំងមិនមានឡើយ កំពែងសន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអាកាស (ប្រាកដ)ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

ចុតិ ច ឧបបត្តិ ច ខណេ តស្មឹ ន វិជ្ជតិ

តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

ចុតិនិងឧបបត្តិ មិនមានក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

( ឥមេ និមិត្តា ទិស្សន្តិ សម្ពោធក្លាយ បាណិនំ )

ឧឡ្ហំ បគ្គយ្ហ វីរិយំ មា និវត្ត អភិក្កម

**មយ៎ំបេតំ ទិជានាម ធុវំ ពុទ្ធោ ភវិស្សសិ ។**

(និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មោធិញ្ញាណ)(ពួកសត្វពោលថា បពិត្រសុមេធតាបស) សូមលោកផ្គង ព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

ព្រះពោធិសត្វ កាលបានស្តាប់ពាក្យព្យាករណ៍របស់ព្រះទសពលទីបង្ករ និងពាក្យរបស់ទេវតាទាំងឡាយ ក្នុងម៉ឺនចក្រវាឡហើយ ក៏កើតឧស្សាហៈឡើងដោយគិតថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ មានឧបមាដូចជាដុំដីដែលគេចោលទៅឰដ៏អាកាស ទៀងតែធ្លាក់មកលើ

ផែនដីវិញ  ឬដូចជាសត្វទាំងឡាយ  ដែលកើតឡើងហើយ ទៀងតែនឹងស្លាប់គ្រប់គ្នា ពុំនោះសោតដូចជារាត្រីដែលអស់ទៅ ព្រះអាទិត្យតែងតែរះឡើង  ក្នុងពួដ៏អាកាស  ឬប្រៀបដូចជា រាជសីហ៍ចេញពីដំណេក  តែងបន្លឺសីហនាទ  ឬមានឧបមា មួយទៀតថា ស្ត្រីដែលមានគភ៌ចាស់ក៏នឹងសម្រាល ដោយពិតប្រាកដ  យ៉ាងណា  ព្រះពុទ្ធដីកា  របស់ព្រះពុទ្ធទាំងឡាយ រមែងពិតប្រាកដ មិនមែនឥតប្រយោជន៍ទេ ក៏មានឧបមេយ្យ យ៉ាងនោះដែរ  អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

ពុទ្ធស្ស វចនំ សុត្វា    ទសសហស្សីន ចូភយំ
តុដ្ឋហដ្ឋា បមោទិតា    ឯវំ ចិន្តេសិហន្តតា ។
អទ្វេជ្ឈវចនា ពុទ្ធា    អមោឃវចនា ជិនា
វិតថំ នត្ថិ ពុទ្ធានំ    ធុវំ ពុទ្ធោ ភវាមិហំ ។

តថាគត លុះឮពាក្យ របស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតាទាំងមួយម៉ឺនចក្រវាឡហើយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ គិតក្នុងកាល នោះ យ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះជិនស្រី ទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីកា របស់ព្រះពុទ្ធទាំងឡាយ មិនដែល ឃ្លៀងឃ្លាតទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ ប្រាកដ ។

**យថា ខិត្តំ នភេ លេឌ្ឌុំ ធុវំ បតតិ ភូមិយំ**

**តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។**

ដុំដីដែលគេចោលទៅ ឰដ៏អាកាស ទៀងតែ ធ្លាក់មកលើផែនដីវិញ យ៉ាងណា ពាក្យរបស់

ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ

យ៉ាងនោះដែរ ។

ទិគថំ នត្ថិ ពុទ្ធានំ ធុវំ ពុទ្ធោ ភវាមិហំ

យថាបិ សព្វសត្តានំ មរណំ ធុវសស្សតំ

តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។

ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះ

ឃ្លៀងឃ្លាត អាត្មាអញ នឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ សេចក្តីស្លាប់របស់សព្វសត្វ ទៀងទាត់

ប្រាកដ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរ

ទាំងឡាយ ទៀងទាត់ប្រាកដ ដូច្នោះដែរ ។

យថា រត្តិក្ខយេ បត្តេ សុរិយុគ្គមនំ ធុវំ

តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។

កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។

**យថា និច្ចន្តសយនស្ស សីហស្ស នទនំ ធុវំ**

**តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។**

សីហៈ ដែលចេញអំពីដំណេក តែងបន្លឺសម្រែង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។

**យថា អាបន្នសត្តានំ ភារមោរោបនំ ធុវំ**

**តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។**

ការសម្រាលគភ៌ នៃស្រីដែលមានគភ៌ធ្ងន់
ជារបស់ទៀងទាត់ យ៉ាងណា ព្រះបន្ទូលរបស់
ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ
យ៉ាងនោះដែរ ។

# សុមេធបណ្ឌិតពិចារណារកពុទ្ធការកធម៌

## ទានបារមីទី ១

សុមេធបណ្ឌិត ធ្វើការជ្រាក់ចុះក្នុងចិត្តយ៉ាងនេះថា អាត្មាអញ នឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ, ដើម្បីពិចារណា ដល់ពុទ្ធការកធម៌ទាំងឡាយ ទើបត្រួតត្រាស្ទាបស្ទង់មើលធម្មធាតុទាំងអស់ដោយលំដាប់ថា ពុទ្ធការកធម៌ទាំងឡាយ មាននៅក្នុងទីណាហ្ន៎! ស្ថិតនៅខាងលើ ឬខាងក្រោម នៅក្នុងទិសធំ ឬទិសតូច? កំពុងតែពិចារណារាវរកពុទ្ធការកធម៌តាមលំដាប់ ក៏បានឃើញទានបារមីទី ១ ដែលបោរាណកពោធិសត្វទាំងឡាយ ធ្លាប់សេព ធ្លាប់អាស្រ័យមកហើយ រួចក៏ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីពេលនេះទៅ អ្នកចូរបំពេញទានបារមីជាដំបូងចុះ ប្រៀបដូចក្អមដែលមានទឹកពេញ បុគ្គលណាមួយ ផ្កាប់ចុះ

ចាក់ទឹកចេញ មិនឲ្យមានសេសសល់ ហើយទឹកនោះឯង ក៏មិនអាចហូរត្រឡប់ ចូលមកវិញបានឡើយ យ៉ាងណា អ្នកកុំក្រឡេកមើលទ្រព្យ យស បុត្រ ភរិយា និងអវយវៈតូចធំ ឡើយ កាលបើមានពួកស្មូមយាចក មកសូមរបស់អ្វី ៗ អ្នកត្រូវតែឲ្យ របស់នោះទាំងអស់ តាមសេចក្ដីត្រូវការ កុំឲ្យមានសេសសល់ឡើយ ក៏យ៉ាងនោះដែរ ។ កាលបើ ឲ្យទានដូច្នេះហើយ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ទៀបគល់ ពោធិព្រឹក្សមិនខានឡើយ ។ លុះពិចារណាឃើញយ៉ាងនេះ ហើយ ក៏អធិដ្ឋាននូវទានបារមីទុកយ៉ាងមាំមួនជាដំបូង ។ ដោយហេតុនោះ ទើបត្រាស់ថា :

ហន្ទ ពុទ្ធករេ ធម្មេ វិចិនាមិ ឥតោចិតោ
ឧទ្ធំ អធោ ទសទិសា យាវតា ធម្មធាតុយា ។

បើដូច្នោះ អាត្មាអញ នឹងជ្រើសរើសរក

ពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះពីខាងនោះ គឺ

ខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់

ធម្មធាតុ ។

**ទិថិនន្តោ គនា ឥត្ថ៊ី បឋមំ ទានបារមី**

**បុព្វកេហិ មហេសីហិ អនុចិណ្ណំ មហាបថំ ។**

**ឥមំ ត្វំ បឋមំ តាវ ទឡ្ហំ កត្វា សមាទិយ**

**ទានបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។**

កាលនោះ តថាគត កំពុងជ្រើសរើស

ក៏បានឃើញទានបារមីជាដំបូង ជាគន្លងធំ ដែល

ពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សន្សំមក

( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត )

អ្នកចូរសមាទាន ធ្វើនូវទានបារមី ជាដំបូងនេះ

ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញាណ ចូរ

បំពេញនូវទានបារមីចុះ ។

យថាបិ កុម្ភោ សម្បុណ្ណោ យស្ស កស្សចិ អធោកតោ
វមតេ ឧទកំ និស្សេសំ ន តត្ថ បរិរក្ខតិ ។
តថេវ យាចកេ ទិស្វា ហីនមុក្កដ្ឋមជ្ឈិមេ
ទទាហិ ទានំ និស្សេសំ កុម្ភោ វិយ អធោកតោ ។

ក្អមដែលមានទឹកពេញ បុគ្គលណាមួយ ផ្កាប់ចុះ ចាក់មិនឲ្យសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទាន កុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ។

# សីលបារមីទី ២

លំដាប់នោះ សុមេធបណ្ឌិត ពិចារណារកបន្ថែមទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ គង់មានធម៌ដទៃក្រៅពីនេះទៀត ។ លុះកំពុងតែពិចារណា ក៏បានឃើញសីលបារមីទី ២ ទើបទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីពេលនេះទៅ អ្នកចូរបំពេញសីលបារមីចុះ ។ សត្វចាមរី តែងរក្សាកន្ទុយរបស់ខ្លួនដោយមិនអាល័យដល់ជីវិត យ៉ាងណា ចាប់ផ្ដើមពីពេលនេះទៅ អ្នកចូររក្សាសីល ដោយមិនអាល័យជីវិត ក៏យ៉ាងនោះដែរ ។ កាលបើរក្សាសីលដូច្នេះហើយ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លុះពិចារណាឃើញយ៉ាងនេះហើយ ក៏អធិដ្ឋានសីលបារមីទី ២ ទុក យ៉ាងមាំមួន ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ

អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ ទុតិយំ សីលបារមឹ

បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

ឥមំ ត្វំ ទុតិយំ តាវ ទឡ្ហំ កត្វា សមាទិយ

សីលបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏ឃើញសីលបារមីទី ២ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត )

អ្នកឯងចូរសមាទាន ធ្វើសីលបារមីទី ២ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។

**យថាបិ ចាមរី វាលំ កិស្មិញ្ចិ បដិលគ្គិតំ**

**ឧបេតិ មរណំ តត្ថ ន វិកោបេតិ វាលធី ។**

**តថេវ ចតូសុ ភូមីសុ សីលានិ បរិបូរយ**

**បរិរក្ខ សព្វទា សីលំ ចាមរី វិយ វាលធី ។**

សត្វចាមរី(កាលឃើញ) រោមកន្ទុយចំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្ដាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឲ្យដូចជាសត្វចាមរី រក្សាកន្ទុយយ៉ាងនោះចុះ ។

# នេក្ខម្មបារមីទី ៣

លំដាប់នោះ សុមេធបណ្ឌិត ពិចារណារាវរកក្រៃលែងថែមទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ។ លុះកំពុងតែពិចារណា ក៏បានឃើញនូវនេក្ខម្មបារមីទី ៣ ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់ផ្តើមពីពេលនេះទៅ អ្នកចូរបំពេញនេក្ខម្មបារមីឲ្យមាំមួន ដូចជាបុរសអ្នកនៅក្នុងគុក មិនមានសេចក្តីត្រេកអរក្នុងគុកនោះឡើយ ដោយពិតរមែងធុញទ្រាន់តែម្យ៉ាង ទាំងមិនប្រាថ្នានៅក្នុងគុកនោះផង យ៉ាងណា អ្នកចូរញ៉ាំងភពទាំងពួងឲ្យដូចជាគុក ចូរប្រាថ្នាការចេញចាកភព បែរមុខទៅរកនេក្ខម្មៈ យ៉ាងនោះដែរ ។ កាលបើអ្នកធ្វើយ៉ាងនេះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លុះពិចារណាឃើញយ៉ាងនេះហើយ ក៏អធិដ្ឋាននេក្ខម្មបារមីទី ៣ ទុកយ៉ាងមាំមួន ។

ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ

អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ តតិយំ នេក្ខម្មបារមឹ

បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

ឥមំ ត្វំ តតិយំ តាវ ទឡ្ហំ កត្វា សមាទិយ

នេក្ខម្មបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលពោធិសត្វ

ទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យ

មក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត)

អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះ

ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរ

បំពេញនូវនេក្ខម្មបារមីចុះ ។

យថា អន្ទុឃរេ បុរិសោ ចិរំ ទុដ្ឋោ ទុក្ខដ្ដិតោ

ន តត្ថ រាគំ អភិជនេតិ មុត្តឹយេវ គវេសតិ ។

តថេវ ត្វំ សព្វភវេ បស្ស អន្ទុឃរេ វិយ

នេក្ខម្មាភិមុខោ ហោហិ ភវតោ បរិមុត្តិយា ។

បុរស ដែលជាប់នៅក្នុងគុក អស់កាលយូរ

ត្រូវសេចក្តីទុក្ខបៀតបៀនហើយ រមែងមិនញុំាង

សេចក្តីត្រេកអរ ឲ្យកើតឡើង ក្នុងគុកនោះទេ

រមែងស្វែងរកការរួច (ចាកគុកនោះ) យ៉ាងណា

អ្នកចូរឃើញនូវភពទាំងអស់ ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មះ ដើម្បីរួចចាកភព យ៉ាងនោះដែរ ។

# បញ្ញាបារមីទី ៤

លំដាប់នោះ សុមេធបណ្ឌិត ពិចារណារាវរក ឲ្យកាន់តែក្រៃលែងជាបន្តទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ ។ លុះកំពុងតែពិចារណា ក៏បានឃើញបញ្ញាបារមីទី ៤ ហើយក៏បានទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត រាប់ចាប់តាំងពីឥឡូវនេះទៅ អ្នកគប្បី បំពេញនូវបញ្ញាបារមីឲ្យបរិបូណ៌ អ្នកមិនត្រូវរំលងបុគ្គល ណាមួយឡើយ ទោះថោកទាប មធ្យម ឬខ្ពង់ខ្ពស់ គប្បី ស្វែងរកបណ្ឌិតដើម្បីសួរនូវបញ្ហា ឲ្យដូចជាភិក្ខុអ្នកប្រព្រឹត្ត បិណ្ឌបាតជាវត្ត រមែងត្រាច់ទៅបិណ្ឌបាត តាមលំដាប់ មិនរំលងត្រកូលទាំងឡាយ មានត្រកូលថោកទាបជាដើមឡើយ ហើយតែងបាននូវអាហារ ល្មមញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកកាលបើត្រាច់រកបណ្ឌិត ដើម្បីសាកសួរបញ្ហា

អ្នកនឹងត្រាស់ជាព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។ លុះពិចារណាឃើញយ៉ាងនេះហើយ ក៏អធិដ្ឋានបញ្ញាបារមីទី ៤ ទុកយ៉ាងមាំមួន ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ

អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀតដែលជាធម៌ញុំាំងពោធិញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ ចតុត្ថំ បញ្ញាបារមី

បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

ឥមំ ត្វំ ចតុត្ថំ តាវ ទឡ្ហំ កត្វា សមាទិយ

បញ្ញាបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក

ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វ

ទាំងឡាយអំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យ

មក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត)

អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះ ឲ្យមាំមួន

បើអ្នកចង់ដល់ នូវពោធិញ្ញាណ ចូរបំពេញនូវ

បញ្ញាបារមីចុះ ។

យថាបិ ភិក្ខុ ភិក្ខន្តោ ហីនមុក្កដ្ឋមជ្ឈិមេ

កុលានិ ន វិវជ្ជន្តោ ឯវំ លភតិ យាបនំ ។

តថេវ ត្វំ សព្វកាលំ បរិបុច្ឆន្តោ ពុធំ ជនំ

បញ្ញាបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។

ភិក្ខុ កាលប្រព្រឹត្តបិណ្ឌបាត មិនវៀរលែង

នូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់

ឬមធ្យម រមែងបានចង្ហាន់ ល្មមញុាំងអត្តភាព ឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជន ជាអ្នកប្រាជ្ញ សព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះ ដែរ ៕

# វីរិយបារមីទី ៥

លំដាប់ភ្លាមនោះ សុមេធបណ្ឌិត ក៏ពិចារណាតទៅទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ ៗ កាលបើកំពុងតែពិចារណា ក៏បានឃើញវីរិយបារមីទី ៥ ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់ពីពេលនេះតទៅ អ្នកចូរបំពេញវីរិយបារមីឲ្យបរិបូណ៌ចុះ ៗ សត្វរាជសីហ៍ ជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរាគ្រប់ឥរិយាបថ យ៉ាងណា អ្នកចូរផ្គងឡើងនូវសេចក្តីព្យាយាម ដោយមិនរួញរា គ្រប់ឥរិយាបថ ក្នុងភពទាំងពួងអ្នកនឹងត្រាស់ជាព្រះពុទ្ធមិនខានឡើយ ក៏យ៉ាងនោះដែរ ៗ លុះពិចារណាឃើញយ៉ាងនេះហើយ ក៏អធិដ្ឋានវីរិយបារមីទី ៥ ទុកយ៉ាងមាំមួន ៗ ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ

អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញាណឲ្យសម្រេច ៗ

វិចិនន្តោ តទា ទក្ខិំ បញ្ចមំ វីរិយបារមី

បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

ឥមំ ត្វំ បញ្ចមំ តាវ ទឡ្ហំ កត្វា សមាទិយ

វីរិយបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះ ឲ្យមាំមួន

បើអ្នកចង់លុះ  នូវពោធិញ្ញាណ  ចូរបំពេញនូវ

វិរិយបារមីចុះ ៕

យថាបិ សីហោ មិគរាជា និសជ្ជដ្ឋានចង្កមេ

អលីនវីរិយោ ហោតិ  បគ្គហិតមនោ សទា ។

តថេវ ត្វំ សព្វភវេ  បគ្គយ្ហ វីរិយំ ទឡ្ហំ

វីរិយបារមិតំ គន្ត្វា  សម្ពោធឹ បាបុណិស្សសិ ។

សត្វសីហៈជាស្តេចនៃម្រឹគ  មានព្យាយាម
មិនរួញរា មានចិត្តផ្គងសព្វកាល ក្នុងការអង្គុយ
ឈរ ដើរ យ៉ាងណា អ្នកគួរផ្គងព្យាយាម
ឲ្យមាំមួន ក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់
នូវវិរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណ
មិនខានឡើយ ៕

# ខន្តិបារមីទី ៦

លំដាប់រំពេចនោះ សុមេធបណ្ឌិត ពិចារណារាវរក បន្ថែមទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ។ កាលបើកំពុងតែពិចារណា ក៏បានឃើញខន្តិបារមីទី ៦ រួចទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីឥឡូវនេះទៅ អ្នកចូរបំពេញខន្តិបារមីចុះ គប្បីជាអ្នកអត់ធន់ទាំងពាក្យសរសើរ ទាំងការតិះដៀល ។ ជនទាំងឡាយដាក់នូវរបស់ស្អាតក្តី របស់មិនស្អាតក្តី លើផែនដី ផែនដីក៏មិនមានសេចក្តីត្រេកអរ ឬថ្នាំងថ្នាក់ ចំពោះវត្ថុទាំងអស់នោះឡើយ យ៉ាងណា អ្នកចូរអត់ធន់ចំពោះការរាប់អាន និងការមើលងាយ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធក៏យ៉ាងនោះដែរ ។ លុះពិចារណាឃើញយ៉ាងនេះហើយ ក៏អធិដ្ឋានខន្តិបារមីទី ៦ ទុកយ៉ាងមាំមួន ។ ព្រោះហេតុនោះ

ទើបត្រាស់ថា ៖

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះ ទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ ឆដ្ឋមំ ខន្តិបារមី
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ ឆដ្ឋមំ តាវ ទឡ្ហំ កត្វា សមាទិយ
តត្ថ អទ្វេជ្ឈមានសោ សម្ពោធឹ បាបុណិស្សសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វ ទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យ

មក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើនូវខន្តិបារមីទី ៦ នេះ ឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ ក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។

**យថាបិ បឋវី នាម　　សុចឹបិ អសុចឹបិ ច**

**សព្វំ សហតិ និក្ខេបំ　　ន ករោតិ បដិឃទ្ធយំ ។**

**តថេវ ត្វំបិ សព្វេសំ　　សម្មានាវមានក្ខមោ**

**ខន្តិបារមិតំ គន្ត្វា　　សម្ពោធឹ បាបុណិស្សសិ ។**

ធម្មតាផែនដីរមែងអត់ទ្រាំ ចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើ នូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំ នូវការរាប់អាន និងការមើលងាយ របស់ពួកជន

ទាំងពួង យ៉ាងនោះដែរ លុះដល់ទូវខន្តិបារមី

ហើយ ទើងបានសម្រេចសម្មោធិញ្ញាណមិនខាន

ឡើយ ។

# សច្ចបារមីធី ៧

លំដាប់ក្នាមនោះ សុមេធបណ្ឌិត ពិចារណាភាវរក ទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែ ប៉ុណ្ណោះទេ ។ កាលបើកំពុងតែពិចារណា ក៏បានឃើញ សច្ចបារមី ៧ ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីពេលនេះទៅ អ្នកចូរបំពេញសច្ចបារមីចុះ ចូរអ្នក កុំគប្បីនិយាយកុហកទាំងដឹងខ្លួន ដោយអគតិណាមួយ មាន ឆន្ទាគតិជាដើម ដើម្បីប្រយោជន៍ដល់ទ្រព្យសម្បត្តិជាអាទិ ទោះបីផ្ទេកបន្ទោរ ធ្លាក់ត្រូវសីសៈរបស់ខ្លួនក៏ដោយ ។ ធម្មតា ផ្កាយព្រឹក តែងដើរតាមទីគោចររបស់ខ្លួន ក្នុងរដូវ ភ្លៀង និងហេមន្តរដូវ មិនត្រាច់ទៅកាន់វិថីដទៃ យ៉ាងណា កាលបើអ្នកពោលពាក្យសច្ចៈ មិននិយាយកុហក អ្នកនឹង បានត្រាស់ជាព្រះពុទ្ធមិនខាន ក៏យ៉ាងនោះដែរ ។ លុះ

ពិចារណាយ៉ាងនេះហើយ ក៏អធិដ្ឋានសច្ចបារមីទី ៧ ទុក

យ៉ាងមាំមួន ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ

អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះ

ទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត

ដែលជាធម៌ញុំាំងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខិំ សត្តមំ សច្ចបារមី

បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

ឥមំ ត្វំ សត្តមំ តាវ ទឡ្ហំ កត្វា សមាទិយ

តត្ថ អទ្វេជ្ឈវចនោ សម្ពោធឹ បាបុណិស្សសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក

ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វ

ទាំងឡាយ អំពីបូរាណធ្លាប់សេព ធ្លាប់អាស្រ័យ

មក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត)

អ្នកចូរសមាទាន ធ្វើសច្ចបារមីទី ៧ នេះ ឲ្យមាំមួន

កុំមានពាក្យបែកជាពីរ ក្នុងសច្ចបារមីនោះ ទើងបាន

សម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

យថាបិ ឱសធិ នាម តុលាភូតា សទេវកេ

សមយេ ឧតុវស្សេ វា ន វោក្កមតិ វីថិតោ ។

តថេវ ត្វំបិ សច្ចេសុ មា វោក្កមសិ វីថិតោ

សច្ចបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។

ធម្មតា ផ្កាយព្រឹក ជាជញ្ជីងរបស់លោក

ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថី ក្នុង

រដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។

អ្នកកុំឃ្លាតចាកវិថី ក្នុងសច្ចៈទាំងឡាយ យ៉ាងនោះ

ដែរ លុះដល់នូវសច្ចបារមីហើយ ទឹងបានសម្រេច

សម្ពោធិញ្ញាណមិនខានឡើយ ។

# អធិដ្ឋានបារមីទី ៨

លំដាប់នោះ សុមេធបណ្ឌិត ពិចារណារកបន្ថែមទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ។ កាលបើកំពុងតែពិចារណា ក៏បានឃើញអធិដ្ឋានបារមីទី ៨ រួចទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីពេលនេះទៅ អ្នកចូរបំពេញអធិដ្ឋានបារមីចុះ ។ កាលបើអធិដ្ឋានវត្ថុណាទុកហើយ គប្បីជាអ្នកមិនញាប់ញ័រក្នុងអធិដ្ឋាននោះ ។ ធម្មតាភ្នំថ្មតាន់ កាលខ្យល់បក់មកត្រូវគ្រប់ទិស រមែងមិនកម្រើក មិនរញ្ជួយ តាំងនៅស៊ប់ក្នុងទីរបស់ខ្លួន យ៉ាងណា អ្នកចូរកុំគប្បីកម្រើកក្នុងអធិដ្ឋានបារមីក៏យ៉ាងនោះដែរ កាលបើដល់នូវអធិដ្ឋានបារមីហើយ នឹងបានត្រាស់ជាព្រះពុទ្ធមិនខានឡើយ ។ លុះពិចារណាឃើញយ៉ាងនេះហើយ ក៏អធិដ្ឋាននូវអធិដ្ឋានបារមីទី ៨ ទុក

យ៉ាងមាំមួន ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀតដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ អដ្ឋមំ អធិដ្ឋានបារមី
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ អដ្ឋមំ តាវ ទឡ្ហំ កត្វា សមាទិយ
តត្ថ ត្វំ និច្ចលោ ហុត្វា សម្ពោធឹ បាបុណិស្សសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរកក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យ

មក(ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត)

អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះ

ឲ្យមាំមួន អ្នកកុំញាប់ញ័រ ក្នុងអធិដ្ឋានបារមីនោះ

នឹងបានសម្រេចសម្ពោធិញាណមិនខានឡើយ ។

យថាបិ បព្វតោ សេលោ អចលោ សុបតិដ្ឋិតោ

ន កម្បតិ ភូសវាតេហិ សកដ្ឋានេវ តិដ្ឋតិ ។

តថេវ ត្វំ អធិដ្ឋានេ សព្វទា អចលោ ភវ

អធិដ្ឋានបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។

ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយ

ដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួន

ដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមី

សព្វកាល យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមី

ហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខាន

ឡើយ ។

# មេត្តាបារមីទី ៩

លំដាប់នោះ សុមេធបណ្ឌិត ពិចារណាការកជាបន្ត ទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ។ កាលបើកំពុងតែពិចារណា ក៏បានឃើញមេត្តាបារមីទី ៩ រូបទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីពេលនេះតទៅ អ្នកចូរបំពេញមេត្តាបារមីចុះ ។ អ្នកគប្បីមានចិត្តស្មើ ចំពោះអំពើដែលមានប្រយោជន៍ផង និងអំពើដែលមិនមានប្រយោជន៍ផង ឧបមាដូចជាទឹក តែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អ ទាំងអាក្រក់យ៉ាងណា អ្នកចូរចម្រើនមេត្តា ចំពោះសព្វសត្វ ក៏យ៉ាងនោះដែរ ។ កាលបើអ្នកដល់នូវមេត្តាបារមីហើយ នឹងសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ លុះបានពិចារណាឃើញយ៉ាងនេះហើយ ក៏អធិដ្ឋានមេត្តាបារមី ទី ៩ ទុកយ៉ាងមាំមួន ។

ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ　　ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ　　យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះ
ទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត
ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ　　នវមំ មេត្តាបារមឹ
បុព្វកេហិ មហេសីហិ　　អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ នវមំ តាវ　　ទឡ្ហំ កត្វា សមាទិយ
មេត្តាយ អសមោ ហោហិ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ　តថាគត　កំពុងជ្រើសរើសរក
ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយ

អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយ

ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរ

សមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះ ឲ្យមាំមួន

អ្នកចូរកុំឲ្យមានបុគ្គលដទៃ ស្មើដោយមេត្តា

បើអ្នកចង់ល្មុះនូវពោធិញ្ញាណ ។

យថាបិ ឧទកំ នាម កល្យាណេ បាបកេ ជនេ

សមំ ផរតិ សីតេន បវាហេតិ រជោមលំ ។

តថេវ ត្វំ ហិតាហិតេ សមំ មេត្តាយ ភាវយ

មេត្តាបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។

ធម្មតាទឹក រមែងផ្សព្វផ្សាយ ត្រជាក់ស្មើ

ចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់

នូវធូលី និងមន្ទិល យ៉ាងណា ។ អ្នកចូរចម្រើន

មេត្តាឲ្យស្មើ ចំពោះមិត្រនិងសត្រូវ យ៉ាងនោះដែរ

លុះដល់នូវមេត្តាបារមីហើយ        នឹងបានសម្រេច

សម្ពោធិញ្ញាណមិនខានឡើយ ។

# ឧបេក្ខាបារមីទី ១០

លំដាប់នោះ សុមេធបណ្ឌិត ត្រិះរិះរកទៀតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ ។ កាលបើកំពុងតែពិចារណា ក៏បានឃើញឧបេក្ខាបារមីទី ១០ របស់ទ្រង់ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីពេលនេះទៅ អ្នកចូរបំពេញឧបេក្ខាបារមីឲ្យបរិបូណ៌ចុះ អ្នកគួរជាជញ្ជីង(ដាក់ខ្លួនទៅជាកណ្ដាល) ទាំងសេចក្ដីសុខ ទាំងសេចក្ដីទុក្ខ ។ ធម្មតាផែនដី តែងតែព្រងើយ ចំពោះបុគ្គលដែលដាក់វត្ថុស្អាតក្ដី វត្ថុមិនស្អាតក្ដី យ៉ាងណា អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីង ចំពោះសុខនិងទុក្ខ ក៏យ៉ាងនោះដែរ ។ កាលបើអ្នកដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្មោធិញ្ញាណមិនខានឡើយ ។ លុះពិចារណាយ៉ាងនេះហើយ ក៏អធិដ្ឋានឧបេក្ខាបារមីទី ១០ ទុកយ៉ាងមាំមួន ។

ព្រោះហេតុនោះ ទើបត្រាស់ថា :

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ

អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ ទសមំ ឧបេក្ខាបារមឹ

បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

ឥមំ ត្វំ ទសមំ តាវ ទឡ្ហំ កត្វា សមាទិយ

តុលាភូតោ ទឡ្ហោ ហុត្វា សម្ពោធឹ បាបុណិស្សសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យ

មក(ហើយទ្រង់ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត)

អ្នកចូរសមាទាន ធ្វើនូវឧបេក្ខាបារមីទី ១០ នេះ

ឲ្យមាំមួន អ្នកគួរជាបុគ្គល ដូចជាជញ្ជីងដ៏មាំមួន

ទើងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។

**យថាបិ បឋវី នាម  និក្ខិត្តំ អសុចឹ សុចឹ**

**ឧបេក្ខតិ ឧភោបេតេ  កោបានុនយវជ្ជិតា ។**

**តថេវ ត្វំ សុខទុក្ខេ  តុលាភូតោ សទា ភវ**

**ឧបេក្ខាបារមិតំ គន្ត្វា  សម្ពោធឹ បាបុណិស្សសិ ។**

ធម្មតាផែនដី តែងព្រងើយកន្តើយ ចំពោះ

វត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ

តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ

ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួន

ឲ្យដូចជាជញ្ជីង ចំពោះសុខ និងទុក្ខ សព្វកាល

យ៉ាងនោះដែរ  អ្នកលុះដល់នូវឧបេក្ខាបារមីហើយ

នឹងបានសម្រេចសម្ពោធិញ្ញាណពុំខាន ។

# ពិចារណាបារមីទាំង ១០ ដោយអនុលោមបដិលោម

បន្ទាប់ពីនោះមក សុមេធបណ្ឌិត គិតថា ពុទ្ធការកធម៌ទាំងឡាយ ជាប្រធាននៃពោធិញ្ញាណ ដែលពោធិសត្វទាំងឡាយ ត្រូវបំពេញក្នុងលោកនេះ ឯពុទ្ធការកធម៌នោះ មិនមែនដទៃក្រៅពីបារមីទាំង ១០ នេះទេ, បារមីទាំង ១០ នោះឯង មិនមែនស្ថិតនៅខាងលើ មិនមែនស្ថិតនៅឯអាកាស មិនមែនស្ថិតនៅខាងក្រោមផែនដី មិនមែនស្ថិតនៅក្នុងទិសទាំងឡាយ មានបុរត្ថិមទិស (ទិសខាងកើត) ជាដើមទេ ប្រាកដជាស្ថិតនៅស៊ប់ ក្នុងហឫទ័យនៃអាត្មាអញនេះឯង ។ សុមេធបណ្ឌិត កាលបើយល់ច្បាស់ថា បារមីទាំងនោះស្ថិតនៅស៊ប់ ក្នុងហឫទ័យយ៉ាងនេះហើយ ក៏អធិដ្ឋានបារមីទាំងអស់ ឲ្យតាំងនៅមាំ ហើយពិចារណារឿយ ៗ ជាអនុលោម (បណ្ដោយចុះទៅ) ជាបដិលោម (ប្រាសត្រឡប់

វិញ) ពោលគឺ ពិចារណាសាចុះសាឡើង ដោយចាប់ពីខាងចុង ត្រឡប់រហូតដល់ខាងដើមនៃបារមី ពីខាងដើមរហូតដល់ខាងចុងនៃបារមី ត្រង់កណ្ដាលទៅបញ្ចប់នៅខាងដើម និងខាងចុងនៃបារមី ព្រមទាំងចាប់ពីខាងដើមនិងខាងចុង ទៅបញ្ចប់នៅត្រង់កណ្ដាល នៃបារមីវិញ, ពិចារណាយ៉ាងនេះ រហូតដល់គ្រប់បារមី ១០ មានទានបារមី (ការបរិច្ចាគទ្រព្យសម្បត្តិ)ជាដើម ឧបបារមី ១០ មានទានឧបបារមី (ការបរិច្ចាគអវយវៈ)ជាដើម បរមត្ថបារមី ១០ មានទានបរមត្ថបារមី(ការបរិច្ចាគជីវិត)ជាដើម ដូចគេបង្វិលគ្រលុកប្រេងក្នុងគ្រឿងយន្ត ពុំនោះសោតដូចគេយកកំពូលភ្នំសិនេរុមកកូរគ្រលុកក្នុងទឹកមហាសមុទ្រ ។ កាលដែលសុមេធបណ្ឌិត កំពុងតែពិចារណានូវបារមីទាំង ១០ ដោយតេជៈនៃធម៌ មហាប្រឹថពី ដែលមានកម្រាស់ ២ សែន

៤ ម៉ឺនយោជន៍ ក៏កម្រើករញ្ជួយរំលញ់រលាន់ឮ ដូចដីរ

ជាន់បាច់បបុស ឬដូចជាស្គូរឃ្មោះដែលគេគាបអំពៅ ។

ព្រោះហេតុនោះ ទើបត្រាស់ថា :

**ឯត្តកាយេវ តេ លោកេ យេ ធម្មា ពោធិបាចនា**

**តទុទ្ធំ នត្ថិ អញ្ញត្រ ទឡ្ហំ តត្ថ បតិដ្ឋហិ ។**

ធម៌ទាំងឡាយណា ជាគ្រឿងញ៉ាំងពោធិ-

ញ្ញាណឲ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោក

ត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃ ក្រៅអំពីបារមី

១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌

ទាំង ១០ នោះ ឲ្យមាំមួនចុះ ។

**ឥមេ ធម្មេ សម្មសតោ សភាវសរសលក្ខណោ**

**ធម្មតេជេន វសុធា ទសសហស្សី បកម្បថ ។**

កាលតថាគតពិចារណា នូវបារមីធម៌ទាំងនេះ

ដោយសភាវសរសេលក្ខណៈ ផែនដីទាំងមួយម៉ឺន

លោកធាតុ ក៏ញាប់ញ័រ ដោយតេជះនៃធម៌ ។

**ចលតិ រវតិ បឋវី ឧច្ឆុយន្តំវ បីឡិតំ**

**គេលយន្តំ យថា ចក្កំ ឯវំ កម្បតិ មេទនី ។**

ផែនដីកម្រើកបន្ទឺឡើង ដូចជាឃ្នាបអំពៅ

ដែលត្រូវគេគាប ឬចក្កយន្តប្រេង ត្រូវគេគាប

ហើយ (រមែងវិលញ័រ) យ៉ាងណា ផែនដី

ក៏ញាប់ញ័រ យ៉ាងនោះដែរ ។

កាលដែលមហាប្រឹថពី កំពុងកម្រើករញ្ជួយយ៉ាងនេះ

ពួកមហាជនអ្នកនៅក្នុងរម្មកនគរទាំងប៉ុន្មាន ដែលនៅត្រៀប

ត្រាជុំវិញព្រះមានព្រះភាគ មិនអាចទប់អាត្មាឲ្យឈរនៅនឹង

បាន ក៏ដួលទ្រេតហាក់ដូចជាដើមឈើធំ ៗ ដែលមានខ្យល់

ព្យុះបោកបក់មកត្រូវ មិនតែប៉ុណ្ណោះឡើយ សូម្បីកាជនៈមានក្អម ឆ្នាំងជាដើម ក៏កម្រើករញ្ជួយប៉ះទង្គិចគ្នាបែកខ្ទេចខ្ទីដែរ ។ ចំណែកខាងមហាជនមានសេចក្តីភិតភ័យតក់ស្លុតមហិមា ក៏នាំគ្នាចូលទៅគាល់ទូលសួរ ព្រះសាស្តាព្រះនាមទីបង្ករថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានដឹងថាតើនេះគឺនាគ ឬភូតយក្ស និងទេវតាណាទីមួយ បណ្តាលឲ្យកម្រើករញ្ជួយនេះទេ សូម្បីមហាជនទាំងពួង ក៏ត្រូវកយន្តរាយទ្រុឌ៏ះបៀតបៀនដែរ តើហេតុល្អ ឬហេតុអាក្រក់ដូចម្តេចនឹងមានដល់លោកនេះ ? សូមព្រះអង្គទ្រង់មេត្តាប្រោសសម្តែងប្រាប់នូវហេតុនោះ ដល់ពួកយើងខ្ញុំព្រះអង្គផង ។

ព្រះសាស្តា កាលបើទ្រង់ព្រះសណ្តាប់ពាក្យ របស់មហាជនហើយ ក៏ត្រាស់ថា អ្នកទាំងឡាយកុំខ្លាចឡើយ កុំគិតឡើយកយន្តរាយ ដែលកើតដោយសារហេតុនេះ នឹងមិនមាន

ដល់អ្នកទាំងឡាយទេ ត្បិតថ្ងៃនេះ តថាគតបានព្យាករណ៍ឲ្យ សុមេធបណ្ឌិតថា នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម ក្នុងកាលអនាគត ។ ឥឡូវនេះ សុមេធបណ្ឌិតនោះ កំពុងតែ ពិចារណា នូវបារមីទាំងឡាយ ដោយអំណាចតេជៈនៃធម៌ របស់សុមេធបណ្ឌិត ដែលបានពិចារណានូវបារមីនោះឯង ក៏បណ្ដាលឲ្យលោកធាតុទាំង ១ ម៉ឺន កម្រើករញ្ជួយបន្លឺ សម្លេងខ្ទរខ្ទារជាអស្ចារ្យដោយព្រម ៗ គ្នា យ៉ាងនេះ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

**យាវតា បរិសា អាសិ ពុទ្ធស្ស បរិវេសនេ**

**បវេធមានា សា តត្ថ មុច្ឆិតា សេតិ ភូមិយំ ។**

បរិស័ទរបស់ព្រះពុទ្ធ មានចំនួនប៉ុន្មាន ក្នុងទី ដែលអង្គាស បរិស័ទនោះ ក៏ញាប់ញ័រដេកជ្រប់ លើផែនដី ក្នុងទីអង្គាសនោះ ។

ឃដានេកសហស្សានិ   កុម្ភីនញ្ច សតា ពហូ

សញ្ចុណ្ណមថិតា តត្ថ   អញ្ញមញ្ញំ បឃដ្ដិតា ។

ឆ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏

ទង្គិចគ្នាបែកខ្ទេចខ្ទីអស់ ក្នុងទីនោះ ។

ឧព្វិគ្គា តសិតា ភីតា   ភន្តា ព្យថិតមានសា

មហាជនា សមាគម្ម   ទីបង្ករមុបាគមុំ ។

កឹ ភវិស្សតិ លោកស្ស   កល្យាណំ អថ បាបកំ

សព្វោ ឧបទ្ទុតោ លោកោ តំ វិនោទេហិ ចក្ខុមា ។

ពួកមហាជន មានចិត្តរន្ធត់តក់ស្លុត ភិតភ័យ

ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយ

ចូលទៅគាល់ព្រះពុទ្ធទីបង្ករ (ហើយទូលសួរថា)

បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់

ដូចម្ដេច នឹងមានដល់មនុស្សលោក លោក
ទាំងមូល ត្រូវសេចក្ដីអន្តរាយ បៀតបៀនហើយ
សូមព្រះអង្គ ទ្រង់មេត្តាប្រោស បន្ទោបង់សេចក្ដី
អន្តរាយនោះចេញ ។

តេសំ គតា សញ្ញាបេសិ ធីបង្ករោ មហាមុនិ
ខិសដ្ឋា ហោថ មា ភាថ ឥមស្មឹ បឋវិកម្បនេ ។
យមហំ អជ្ជ ព្យាកាសឹ ពុទ្ធោ លោកេ ភវិស្សតិ
ឯសោ សម្មសតី ធម្មំ បុព្វកំ ជិនសេវិតំ ។

គ្រានោះ ព្រះមហាមុនីទីបង្ករ ទ្រង់ញ៉ាំង
មហាជនទាំងនោះ ឲ្យយល់ច្បាស់ថា អ្នក
ទាំងឡាយ ចូរកុំមានសេចក្ដីរង្កៀស កុំខ្លាចចំពោះ
ការញ៉ាប់ញ៉័រផែនដីនេះឡើយ ។ ត្បិតតថាគត
បានព្យាករ ក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ

នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក (ក្នុងកាលជាអនាគត) សុមេធបណ្ឌិតនុ៎ះ កំពុងពិចារណាធម៌ ដែលព្រះជិនស្រីអំពីបូរាណធ្លាប់សេពមក ៗ

**តស្ស សម្មសតោ ធម្មំ ពុទ្ធភូមិមសេសតោ**

**តេនាយំ កម្បតី បឋវី ឧសសហស្សី សទេវកេ ។**

កាលសុមេធបណ្ឌិត ពិចារណាធម៌គឺពុទ្ធភូមិដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុក្នុងលោក ព្រមទាំងទេវលោកញាប់ញ័រ ៗ

ពួកមហាជន កាលបើបានស្តាប់ នូវព្រះពុទ្ធដីកានៃព្រះតថាគតហើយ ក៏មានចិត្តត្រេកអរីករាយ នាំគ្នាយកផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ ចេញពីរម្មកនគរ ចូលទៅបូជាសុមេធបណ្ឌិត ជាអង្គពោធិសត្វ

ហើយថ្វាយបង្គំ និងធ្វើប្រទក្សិណព្រះពោធិសត្វ រួចក៏ចូលទៅកាន់រម្មកនគរវិញ ។ ចំណែកព្រះពោធិសត្វ ពិចារណានូវបារមីទាំងអស់សព្វគ្រប់ហើយ ក៏តាំងសេចក្ដីព្យាយាមដោយអធិដ្ឋានយ៉ាងមាំមួន រួចហើយក៏ក្រោកចាកអាសនៈ ។ ព្រោះហេតុនោះ ទើបត្រាស់ថា :

ពុទ្ធស្ស វចនំ សុត្វា មនោ និព្វាតិ តាវទេ
សព្វេ មំ ឧបសង្កម្ម បុនបិ អភិវន្ទិសុ ។

ចិត្ត(នៃមហាជន) ក៏រលត់ស្ងប់ ក្នុងខណៈ
នោះភ្លាម ព្រោះបានស្ដាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ
ពួកមហាជនទាំងអស់គ្នា ក៏ចូលមករកេតជាគត
ហើយក្រាបថ្វាយបង្គំម្ដងទៀត ។

សមាទយិត្វា ពុទ្ធគុណំ ទឡ្ហំ កត្វាន មានសំ
ធីបង្ករំ នមស្សិត្វា អាសនា វុដ្ឋហឹ តទា ។

គ្រានោះ តថាគត សមាទាននូវពុទ្ធគុណ

ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយបង្គំ ព្រះពុទ្ធទីបង្ករ

ហើយក្រោកចាកអាសនៈ ។

លំដាប់ពីនោះ ពួកទេវតាទាំងម៉ឺនចក្រវាឡ ប្រជុំគ្នាបូជាព្រះពោធិសត្វ ដោយផ្កាកម្រង និងគ្រឿងក្រអូបជាទិព្វ ហើយពោលសរសើរ ព្រមទាំងឲ្យពរស័ព្ទសាធុការដល់ព្រះពោធិសត្វថា បពិត្រសុមេធតាបស សេចក្ដីប្រាថ្នាដ៏ធំដែលលោកតាំងទុកទៀបបាទមូល នៃព្រះទសពលទីបង្ករក្នុងថ្ងៃនេះ សូមឲ្យសេចក្ដីប្រាថ្នានោះ សម្រេចដល់លោកកុំបីមានអន្តរាយឡើយ ភ័យក្ដី សេចក្ដីតក់ស្លុតក្ដី កុំបីកើតមានដល់លោកឡើយ រោគសូម្បីតិចតួច ក៏កុំបីកើតមានដល់សរីរៈ របស់លោកឡើយ សូមលោកបំពេញនូវបារមីទាំងឡាយ ដើម្បីឲ្យបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ

ធាប់ ៗ ចុះ ប្រៀបដូចដើមឈើគួរផល់ផ្លូវផ្កា គួរផល់ផ្លូវផ្លែហើយ ក៏បញ្ចេញផ្កា បញ្ចេញផ្លែក្នុងសម័យដ៏គួរយ៉ាងណាមិញ លោកចូរបានន្ទូវសម្មាសម្ពោធិញ្ញាណដ៏ឧត្តមដោយរួសរាន់ កុំកន្លងនូវសម័យដ៏គួរនោះឡើយ ក៏យ៉ាងនោះដែរ ។ ពួកទេវតាទាំងឡាយ លុះបានពោលសរសើរព្រមទាំងឲ្យពរសព្ទសាធុការ ដល់ព្រះពោធិសត្វយ៉ាងនេះហើយ ក៏វិលទៅកាន់ទៅស្ថានរបស់ខ្លួន ៗ វិញ ។ ចំណែកខាងព្រះពោធិសត្វ លុះបានទទួលនូវការសរសើរនិងពរជ័យអំពីទេវតាទាំងឡាយហើយ ក៏គិតថា អាត្មាអញនឹងបំពេញបារមីទាំង ១០ ពិតជានឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងរវាងកាលកន្លងទៅ ៤ អសង្ខេយ្យ និង ១ សែនកប្បយ៉ាងប្រាកដ ។ កាលបើគិតយ៉ាងនេះហើយ ក៏អធិដ្ឋាននូវសេចក្តីព្យាយាមដ៏មាំ រួចចូលឈានហោះឡើងកាន់នភាល័យ

ចូលទៅកាន់ព្រៃហិមពាន្តវិញ ។ ព្រោះហេតុនោះ ទើប

ត្រាស់ថា :

**ធិតុំ មានុស្សិកំ បុច្ឆំ ទេវា មានុសកា ឧភោ**

**សមោគិរន្តិ បុប្ផេហិ ខុជ្ជាហន្តស្ស អាសនា ។**

ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយ

រាយផ្កាទិព្វ និងផ្កាជារបស់មនុស្ស ចំពោះ

សុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។

**វេទយន្តិ ច តេ សោត្ថឹ ទេវា មានុសកា ឧភោ**

**មហន្តំ បត្ថិតំ តុយ្ហំ តំ លភស្សុ យថិច្ឆិតំ ។**

ពួកទេវតា និងពួកមនុស្ស ទាំងពីរពួកនោះ

បាននូវសួស្តី(ពោលថា) តំណែងដ៏ធំ ដែលលោក

ប្រាថ្នាហើយ សូមលោកបាន នូវតំណែងនោះ

សមគួរតាមប្រាថ្នាចុះ ។

សព្វីតិយោ វិវជ្ជន្តុ សោកោ រោគោ វិវជ្ជតុ
មា តេ ភវត្វន្តរាយោ ផុស្ស ខិប្បំ ពោធិមុត្តមំ ។

ចង្រៃទាំងពួង ចូរបវៀសជៀសចេញទៅ
សេចក្ដីសោកនិងរោគ ក៏ចូរជៀសវាងចេញទៅ
សេចក្ដីអន្តរាយ កុំបីមានដល់លោកឡើយ សូម
លោកបានលុះ នូវសព្វញ្ញុតញ្ញាណ ដ៏ខ្ពង់ខ្ពស់
ឆាប់ ៗ ចុះ ។

យថា សមយេ សម្បត្តេ បុប្ផន្តិ បុប្ផិនោ ទុមា
តថេវ ត្វំ មហាវីរ ពុទ្ធញ្ញាណេន បុប្ផសិ ។

កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែង
បញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាម
ធំ លោកចូរបញ្ចេញផ្កា ដោយពុទ្ធញ្ញាណ យ៉ាង
នោះដែរ ។

យថា យេ កេចិ សម្ពុទ្ធា បូរយុំ ទសបារមី

គតេទ គុំ មហាវីរ បូរយ ទសបារមី ។

ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញ

ហើយ នូវបារមីទាំង ១០ យ៉ាងណា បពិត្រ

តាបសមានព្យាយាមធំ លោកចូរបំពេញបារមី

ទាំង ១០ យ៉ាងនោះ ៗ

យថា យេ កេចិ សម្ពុទ្ធា ពោធិមណ្ឌម្ហិ ពុជ្ឈរេ

គតេទ គុំ មហាវីរ ពុជ្ឈស្សុ ជិនពោធិយំ ។

ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់

ដឹង ទៀបគល់ពោធិមណ្ឌ: យ៉ាងណា បពិត្រ

តាបសមានព្យាយាមធំ លោកចូរត្រាស់ដឹង ទៀប

គល់ពោធិមណ្ឌ: នៃព្រះជិនស្រី យ៉ាងនោះ ៗ

យថា យេ កេចិ សម្ពុទ្ធា ធម្មចក្កំ បវត្តយុំ

តេជេន ត្វំ មហាវីរ ធម្មចក្កំ បវត្តយ ។

ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំង

ធម្មចក្រឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបស

មានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្រ ឲ្យ

ប្រព្រឹត្តទៅ យ៉ាងនោះចុះ ។

បុណ្ណមាយំ យថា ចន្ទោ បរិបុណ្ណោ វិរោចតិ

តេជេន ត្វំ បុណ្ណមនោ វិរោច ទសសហស្សិយំ ។

ព្រះចន្ទ្រពេញវង់ រមែងរុងរឿង ក្នុងថ្ងៃ

ពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ

បូររុងរឿងក្នុងលោកធាតុទាំងមួយម៉ឺន យ៉ាងនោះ ។

រាហុមុត្តោ យថា សុរិយោ តាបេន អតិរោចតិ

តេជេន លោកា មុញ្ចិត្វា វិរោច សិរិយា តុវំ ។

ព្រះអាទិត្យ ដែលរួចផុតអំពីរាហុ រមែង

រុងរឿងដោយកម្តៅ យ៉ាងណា លោកចូររួចចាក

លោកធម៌ ចូររុងរឿងដោយពុទ្ធសិរី យ៉ាងនោះ

ដែរ ។

យថា យា កាចិ នទិយោ ឱសរន្តិ មហោទធឹ

ឯវំ សទេវកា លោកា ឱសរន្តិ តវន្តិកេ ។

ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំ

ក្នុងមហាសមុទ្រ យ៉ាងណា ពួកលោក ព្រមទាំង

ទេវលោក ក៏រមែងប្រជុំក្នុងសំណាក់របស់លោក

យ៉ាងនោះដែរ ។

តេហិ ថុតិប្បសត្ថោ សោ ទសធម្មេ សមាទិយ

តេ ធម្មេ បរិបូរេន្តោ បវនំ បាវិសី តទា ។

គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួក

ទេវតា និងមនុស្សទាំងនោះ ស្ញើចសរសើរហើយ

ក៏សមាទាននូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំ ។

ចំណែកខាងមហាជន ដែលនៅក្នុងរម្មកនគរទាំងប៉ុន្មាន កាលបើចូលទៅកាន់នគរវិញហើយ ក៏ថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តាលុះសោយនូវចង្ហាន់ស្រេចហើយ ព្រះអង្គក៏សម្តែងព្រះធម៌ញ៉ាំងមហាជនទាំងនោះ ឲ្យតាំងនៅក្នុងគុណទាំងឡាយ មានសរណគមន៍ជាដើម រួចស្តេចយាងចេញពីរម្មកនគរ តាមពុទ្ធអធ្យាស្រ័យ ។ តពីនោះមក ទ្រង់បំពេញពុទ្ធកិច្ចទាំងពួងសព្វគ្រប់ តាមលំដាប់លំដោយ ដរាបដល់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

**ប្រវត្តិសុមេធបណ្ឌិត ចប់**

# មាតិកាធម៌ផ្សេង ៗ

## លក្ខណាទិចតុក្កៈរបស់បារមី(បរមត្ថទីបនី)

### ១. ទានបារមី

- **បរិច្ចាគលក្ខណា** មានការបរិច្ចាគ ជាលក្ខណៈ ។

- **ទេយ្យធម្ម លោភវិទ្ធំសនរសា** មានការកម្ចាត់បង់នូវលោភៈក្នុងទេយ្យធម៌ ជារស ។

- **អនាសត្តិបច្ចុបដ្ឋានា** មានភាពអង់អាច ជាបច្ចុបដ្ឋាន ។

- **ភវវិភវសម្បត្តិបច្ចុបដ្ឋានា វា** ឬមានភវសម្បត្តិនិងវិភវសម្បត្តិ ជាបច្ចុបដ្ឋាន ។

- **បរិច្ចជិតព្វវត្ថុបទដ្ឋានា** មានវត្ថុសមគួរ សម្រាប់បរិច្ចាគ ជាបទដ្ឋាន ។

## ២. សីលបារមី

- សីលនលក្ខណា មានការវៀរចាក(ទុច្ចរិត) ជាលក្ខណៈ ។

- ទុស្សីល្យវិទ្ធំសនរសា មានការកម្ចាត់បង់នូវភាពទ្រុស្តសីល ជារស ។

- អនវជ្ជរសា វា ឬមានសេចក្តីមិនមានទោសជារស ។

- សោចេយ្យបច្ចុបដ្ឋានា មានភាពស្អាតបរិសុទ្ធជាបច្ចុបដ្ឋាន ។

- ហិរោត្តប្បបទដ្ឋានា មានហិរិ និងឱត្តប្បៈជាបទដ្ឋាន ។

## ៣. នេក្ខម្មបារមី

- កាមតោ ច ភវតោ ច និក្ខមនលក្ខណា

មានការចេញចាកកាម និងការត្រេកត្រអាលក្នុងកព ជាលក្ខណៈ ។

- **គណាធិនខវិភាខនរសា** មានការប្រកាសទោសរបស់កាមនោះ ជារស ។

- **គរតោ ៦៥ ទិម្មុខភាខបច្ចុបដ្ឋានា** មានការបែរមុខចេញចាកពីទោសនោះឯង ជាបច្ចុបដ្ឋាន ។

- **សំខេគបធដ្ឋានា** មានសេចក្តីសង្វេគ ជាបទដ្ឋាន ។

## ៤. បញ្ញាបារមី

- **យថាសភាខបដិវេធលក្ខណា** មានការបោក់ធ្លុះតាមសភាវៈ ជាលក្ខណៈ ។

- **អក្ខលិតបដិវេធលក្ខណា** ៦ា ឬមានការដឹងច្បាស់ប្រាកដមិនឃ្លៀងឃ្លាត ជាលក្ខណៈ ។

- វិសយោភាសនរសា មានការក្រើបប្រាស់តាមវិសយៈ(អារម្មណ៍) ជារស ។

- អសម្មោហបច្ចុបដ្ឋានា មានការមិនវង្វេង ជាបច្ចុបដ្ឋាន ។

- សមាធិបទដ្ឋានា មានសមាធិ ជាបទដ្ឋាន ។

- ចតុសច្ចបទដ្ឋានា ខា ឬមានអរិយសច្ចៈធម៌ ៤ ជាបទដ្ឋាន ។

## ៥. វីរិយបារមី

- ឧស្សាហលក្ខណា មានសេចក្តីព្យាយាម ជាលក្ខណៈ ។

- ឧបត្ថម្ភនរសា មានការឧបត្ថម្ភ(នូវសហជាតធម៌) ជារស ។

- **អសំសីទនបច្ចុបដ្ឋានា** មានការមិនធ្លាក់ចុះ (ក្នុងអកុសលធម៌) ជាបច្ចុបដ្ឋាន ។

- **វីរិយារម្ភវត្ថុបទដ្ឋានា** មានវត្ថុជាគ្រឿងសម្រាប់ប្រារព្ធនូវសេចក្ដីព្យាយាម ជាបទដ្ឋាន ។

- **សំវេគបទដ្ឋានា វា** ឬមានសេចក្ដីសង្វេគ ជាបទដ្ឋាន ។

## ៦. ខន្តិបារមី

- **ខមនលក្ខណា** មានសេចក្ដីអត់ធន់ ជាលក្ខណៈ ។

- **ឥដ្ឋានិដ្ឋសហនរសា** មានការអត់ធន់ចំពោះឥដ្ឋា-រម្មណ៍ និងអនិដ្ឋារម្មណ៍ ជារស ។

- **អធិវាសនបច្ចុបដ្ឋានា** មានការអត់ទ្រាំបាន ជាបច្ចុបដ្ឋាន ។

- អវិរោធបច្ចុបដ្ឋានា ខា ឬមិនមានសេចក្ដីក្រោធ ជាបច្ចុបដ្ឋាន ។

- យថាភូតទស្សនបទដ្ឋានា មានការយល់ឃើញតាមសេចក្ដីពិត ជាបទដ្ឋាន ។

## ៧. សច្ចបារមី

- អវិសំវាទនលក្ខណា មានការមិនពោលពាក្យកុហក ជាលក្ខណៈ ។

- យថាសភាវវិភាវនរសា មានការប្រកាសតាមសេចក្ដីពិត ជារស ។

- សាធុតាបច្ចុបដ្ឋានា មានការត្រជាក់ត្រជុំនៃចិត្ត ជាបច្ចុបដ្ឋាន ។

- សោរច្ចបទដ្ឋានា មានសេចក្ដីស្ងប់ ជាបទដ្ឋាន ។

## ៨. អធិដ្ឋានបារមី

- ពោធិសម្ភាររសុ អធិដ្ឋានលក្ខណា មានការតាំងចិត្តមាំក្នុងពោធិសម្ភារ ជាលក្ខណៈ ។

- តេសំ បដិបក្ខាភិភវនរសា មានការគ្របសង្កត់លើឧបសគ្គ ដែលជាបដិបក្ខនៃពោធិសម្ភារនោះ ជារស ។

- តត្ថ អចលតាបច្ចុបដ្ឋានា មានការមិនកម្រើកញាប់ញ័រចំពោះឧបសគ្គ ដែលជាបដិបក្ខនោះ ជាបច្ចុបដ្ឋាន ។

- ពោធិសម្ភារបទដ្ឋានា មានពោធិសម្ភារ ជាបទដ្ឋាន ។

## ៩. មេត្តាបារមី

- ហិតាការប្បវត្តិលក្ខណា មានការប្រព្រឹត្តទៅក្នុងអាការៈ ធ្វើនូវអំពើជាប្រយោជន៍ (ដល់អ្នកដទៃ) ជា

លក្ខណៈ ។

- ហិតូបសំហាររសា មានការនាំនូវប្រយោជន៍ចូលទៅ ជារស ។

- អាឃាតវិនយនរសា ឬមានការកម្ចាត់បង់នូវអាឃាត ជារស ។

- សោម្មភាវបច្ចុបដ្ឋានា មានសេចក្ដីសុភាពរាបសា ជាបច្ចុបដ្ឋាន ។

- សត្តានំ មនាបភាវទស្សនបទដ្ឋានា មានការឃើញនូវភាវៈគួរជាទីរីករាយ ចំពោះសត្វទាំងឡាយ ជាបទដ្ឋាន ។

## ១០. ឧបេក្ខាបារមី

- មជ្ឈត្តាការប្បវត្តិលក្ខណា មានកិរិយាប្រព្រឹត្តទៅ

ដោយអាការៈជាកណ្តាល ជាលក្ខណៈ ។

- **សមតាទស្សនរសា** មានការឃើញនូវភាព ស្មើគ្នា ជារស ។

- **បដិឃានុនយវូបសមបច្ចុបដ្ឋានា** មានការស្ងប់ សេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ ជាបច្ចុបដ្ឋាន ។

- **កម្មស្សកតាបច្ចវេក្ខណបទដ្ឋានា** មានការ ពិចារណា ឃើញថា សត្វមានកម្មជារបស់ខ្លួន ជាបទដ្ឋាន ។

ឋាន

## ទីចង្ក្រមប្រកបដោយទោស ៥ ប្រការ (១)

១-ថទ្ធវិសមតា (ជាកន្លែងរឹងទឹងរដិបរដុប)

២-អន្តោរុក្ខតា(មានដើមឈើនៅខាងក្នុង)

៣- គហនច្ឆន្នតា (ជាទីបិទប្រក់ដោយព្រៃក្រាស់)

៤- អតិសម្ពាធនតា (ជាទីចង្អៀតហួស)

៥- អតិសាលតា (ជាទីធំទូលាយហួស) ។

---

១-អដ្ឋសាលិនី ជាតកដ្ឋកថា និងមធុរត្ថវិលាសិនី ។

# អភិញ្ញាពលៈប្រកបដោយគុណ ៨ ប្រការ[១]

អភិញ្ញាពលៈដែលប្រកបដោយគុណ ៨ ប្រការនោះ សម្ដៅយកសេចក្ដី សុខ ៨ យ៉ាង របស់សមណៈ គឺ :

១- មិនមានសេចក្ដីហួងហែង ចំពោះវត្ថុទាំងឡាយ មានទ្រព្យ និងស្រូវជាដើម ។

២- ស្វែងរកតែបិណ្ឌបាតដែលប្រាសចាកទោស ។

៣- បរិភោគតែបិណ្ឌបាតដែលឆ្អិនស្រាប់ ។

៤- រមែងរួចចាកពីការរឹបអូស ក្នុងកាលដែលពួករាជត្រកូល រឹបអូសយកទ្រព្យសម្បត្តិ ដែលមានតម្លៃ និងទាសៈប្រុសស្រី ព្រមទាំងកហាបណៈជាដើម ។

៥- មិនមានឆន្ទរាគៈ ក្នុងគ្រឿងសម្ភារៈទាំងឡាយ ។

៦- មិនមានការភ័យខ្លាច ព្រោះចោរប្លន់ ។

៧- មិនប្រឡូកប្រឡល់ជាមួយព្រះរាជា និងអាមាត្រ ។

៨- មិនមានទើសទាក់ក្នុងទិសទាំង ៤ ។

---

១-អដ្ឋសាលិនី ជាតកដ្ឋកថា និងមធុរត្ថវិលាសិនី ។

## សំពត់សាដកប្រកបដោយទោស ៩ ប្រការ[១]

១- សំពត់នោះមានតម្លៃច្រើន ។

២- សំពត់ ដែលកើតឡើង ដោយសារជាប់ទាក់ទង ជាមួយនឹងអ្នកដទៃ ។

៣- សំពត់ រមែងប្រឡាក់ដោយងាយ ព្រោះការប្រើ ប្រាស់ កាលបើប្រឡាក់ហើយ ត្រូវគក់និងជ្រលក់ថែម ទៀត ។

៤- កាលបើ សំពត់ចាស់ដោយសារ ការប្រើប្រាស់ ត្រូវដេរប៉ះឡើងវិញ ។

៥- ស្វែងរកសំពត់ថ្មីបានដោយលំបាក ។

៦- សំពត់សាដកជារបស់ដែលមិនសមគួរ ដល់ការ បួសជាតាបស ។

---

១-អដ្ឋសាលិនី ជាតកដ្ឋកថា និងមធុរត្ថវិលាសិនី ។

៧- ត្រូវគ្រប់គ្រងរក្សាដើម្បីកុំឲ្យគេលួចបាន ព្រោះថា សំពត់ជារបស់ទូទៅដល់ពួកចោរ ។

៨- សំពត់ជាគ្រឿងប្រដាប់របស់អ្នកប្រើប្រាស់ ។

៩- ជាសំពត់សម្រាប់ប្រើប្រាស់ប្រចាំខ្លួន របស់អ្នកដើរទៅ ដែលគេតែងតែត្រូវការច្រើន ។

# សំពត់សម្បកឈើប្រកបដោយគុណ ១២ ប្រការ[១]

១- ជាសំពត់មានតម្លៃតិច(ថោក) ។

២- មិនជាប់ទាក់ទងជាមួយនឹងអ្នកដទៃ ។

៣- អាចធ្វើបានដោយដៃខ្លួនឯង ។

៤- សូម្បីចាស់ទៅដោយការប្រើប្រាស់ ក៏មិនចាំបាច់ដេរ ។

៥-មិនមានចោរភ័យ ។

៦- ស្វែងរកបានដោយងាយ ។

៧- ជាសំពត់ដែលសមគួរដល់អ្នកបួសជាតាបស ។

៨- មិនមែនជាសំពត់សម្រាប់ជាគ្រឿងប្រដាប់ របស់អ្នកប្រើប្រាស់ ។

---

១-អដ្ឋសាលិនី ជាតកដ្ឋកថា និងមធុរត្ថវិលាសិនី ។

# បណ្ណសាលាប្រកបដោយទោស ៨ ប្រការ[(១)]

១- ការកសាងត្រូវប្រើប្រាស់ គ្រឿងសម្ភារៈច្រើន ។

២- ត្រូវត្រៀមស្មៅ ស្លឹកឈើ និងដីឥដ្ឋជាដើម ជានិច្ច ។

៣- ជម្មតា សេនាសនៈរមែងទ្រុឌទ្រោម កាលក្រោកឡើងជួសជុល ក្នុងកាលមិនសមគួរ តែងមិនមានឯកគ្គតាចិត្ត ។

៤- ត្រូវទ្រុឌទ្រោមរាងកាយព្រោះត្រូវត្រជាក់ ក្តៅ ។

៥- បុគ្គលអ្នកចូលទៅកាន់ផ្ទះ អាចធ្វើនូវអំពើអាក្រក់ណាមួយបាន ព្រោះថាផ្ទះគឺជាគ្រឿងបិទបាំង នូវពាក្យតិះដៀល ។

---

១-អដ្ឋសាលិនី ជាតកដ្ឋកថា និងមធុរត្ថវិលាសិនី ។

៦- តែងហួងហែងថា នេះជាផ្ទះរបស់អញ ។

៧- ធម្មតា កាលបើមានផ្ទះ ជាការសម្តែងឲ្យឃើញ ថា ត្រូវមានករិយា ។

៨- ជាសាធារណៈដល់សត្វទាំងឡាយ មានសុចជីញ្ជក់ ទិងតុកកែជាដើម ។

# គល់ឈើប្រកបដោយគុណ ១០ ប្រការ[១]

១- មានការខ្វល់ខ្វាយតិច ។

២- មិនមានទោស គឺគ្រាន់តែចូលទៅនៅ ក៏អាចនៅបាន មិនចាំបាច់មើលថែរក្សា ។

៣- អាចញ៉ាំងនូវអនិច្ចសញ្ញាឲ្យកើតឡើង ដោយសារឃើញការប្រែប្រួលរបស់ដើមឈើ និងគល់ឈើ ។

៤- មិនមានសេចក្ដីអាល័យចំពោះសេនាសនៈ(ផ្ទះ) ។

៥- មិនមានទីបិទបាំង ក្នុងការធ្វើនូវអំពើអាក្រក់ព្រោះថា កាលបើធ្វើនូវអំពើអាក្រក់ទៀបគល់ឈើ តែងមានសេចក្ដីអៀនខ្មាស ។

៦- មិនមានសេចក្ដីហួងហែង ។

៧- នៅរួមជាមួយនឹងទេវតាទាំងឡាយ ។

---

១-មធុរត្ថវិលាសិនី ។

៨- បដិសេធទឹកកំប៉ុង ។

៩- ប្រើប្រាស់បានដោយងាយស្រួល ។

១០- មិនមានសេចក្តីអាឡោះអាល័យ ព្រោះគល់ឈើជាសេនាសនៈ ដែលរកបានដោយងាយ ។

# ធម្មសមោធាន ៨ យ៉ាង [១]

ព្រះបរមពោធិសត្វគ្រប់ព្រះអង្គ មុននឹងទទួលការព្យាករណ៍ អំពីព្រះសម្មាសម្ពុទ្ធអង្គណាមួយ ជាលើកដំបូង (ទី១) ដើម្បីបានជានិយតពោធិសត្វ ទៀងតែត្រាស់ដឹងជាព្រះពុទ្ធនោះ លុះណាតែប្រកបដោយអង្គ ៨ ដែលហៅថា អដ្ឋធម្មសមោធាន(ការប្រជុំប្របួមនូវធម៌ទាំងឡាយ ៨) គឺ :

១- មនុស្សត្តំ ភាពជាមនុស្ស ។

២- លិង្គសម្បត្តិ ដល់ព្រមដោយភេទ គឺបុរស ។

៣- ហេតុ ប្រកបដោយហេតុ គឺមានឧបនិស្ស័យគួរនឹងបានសម្រេចអរហត្តផលក្នុងអត្តភាពនោះ ។

៤- សត្ថារទស្សនំ បានជួបនឹងព្រះសាស្តា គឺ

---

១-ប្រសិនបើចង់ដឹងសេចក្តីបន្ថែម នៃធម្មសមោធានទាំង ៨ សូមមើលនៅក្នុងជាតកដ្ឋកថា មធុរត្ថវិលាសិនី និងបរមត្ថទីបនី(អដ្ឋកថាចរិយាបិដក) ។

ព្រះសម្មាសម្ពុទ្ធដោយផ្ទាល់ ។

៥- **បព្វជ្ជា** បានបួសជាតាបស ឬភិក្ខុសង្ឃ ដែលជាកម្មកិរិយាភាពទី ។

៦- **គុណសម្បត្តិ** ដល់ព្រមដោយគុណធម៌ទាំងឡាយ មានអភិញ្ញាជាដើម ។

៧- **អធិការោ** ប្រកបដោយអធិការ គឺមានការ កសាងដ៏ខ្ពង់ខ្ពស់ បូជាដល់ព្រះសម្មាសម្ពុទ្ធ មានជីវិតបរិច្ចាគ ជាដើម ។

៨- **ឆន្ទតា** មានសេចក្តីពេញចិត្តដ៏ខ្លាំងក្លា ក្នុងការ ប្រាថ្នានូវពោធិញ្ញាណ ។

# អ្នកជួយពិនិត្យខ្លឹមសារនិងអក្ខរាវិរុទ្ធ

ភិក្ខុ កោសលប្បញ្ញោ ខួច ពិសិដ្ឋ

វិនយាចារ្យ សីលសំវរោ ស៊ូ សាមុត

សាមណេរ ព្រហ្មឃោសកោ ឈិត ប៊ុនធឿន

សាមណេរ ខន្តិធរោ ជឹម បូរិន

សាមណេរ សីលធរោ ប៊ិច ទណ្ណានុច

សាមណេរ បញ្ញាបរមោ ប្រាក្ដ ស៊ីណា

# ឯកសារពិគ្រោះ

- សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំស ។
- សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ។
- អដ្ឋកថា ខុទ្ទកនិកាយ ជាតក ។
- អដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណី ។
- មធុរត្ថវិលាសិនី អដ្ឋកថា ខុទ្ទកនិកាយ ពុទ្ធវំស ។
- បរមត្ថទីបនី អដ្ឋកថា ខុទ្ទកនិកាយ ចរិយាបិដក ។
- ពុទ្ធប្បវត្តិ ទូរេនិទាន របស់គណៈកម្មការធម្មវិន័យ ក្នុងពុទ្ធសករាជ ២៥៣៤ ។
- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ។